មជ្ឈមណ្ឌលឯកសារកម្ពុជា

**អ៊ិត ហឿន ហៅម៉ូម, ភេទប្រុស K07266 (បាត់ខ្លួន)**

**តួនាទីៈ ប្រធានផ្នែករទេះភ្លើងបាត់ដំបង**

**សម្ភាសជាមួយ ឡូម យ៉េត, អាយុ៦៨ឆ្នាំ, ត្រូវជាប្រពន្ធ**

**ភូមិអូរស្រឡៅ ឃុំអូរដំបង១ ស្រុកសង្កែ ខេត្តបាត់ដំបង**

**ថ្ងៃទី១៦ កក្កដា ២០០៦**

*សំភាសដោយៈ វ៉ា ផៃវ៉ាន់*

រ្សេវ ១១៤

**ផៃវ៉ាន់ៈ** លោកយាយឈ្មោះអីដែរ?

**យ៉េតៈ** ខ្ញុំឈ្មោះយ៉េត, ឡូម យ៉េត ។

**ផៃវ៉ាន់ៈ** សព្វថ្ងៃលោកយាយអាយុប៉ុន្មានហើយ?

**យ៉េតៈ** ៦៨ឆ្នាំ ។

**ផៃវ៉ាន់ៈ** លោកយាយមានស្រុកកំណើតកើតជានៅណាដែរ?

**យ៉េតៈ** នៅតែនេះឯង ។

**ផៃវ៉ាន់ៈ** ភូមិអូរស្រឡៅ ឃុំអូដំបង?

**យ៉េតៈ** ចា៎ស!

**ផៃវ៉ាន់ៈ** កាលពីសង្គមគេដាក់តែអូរដំបងទទេទេហ៎?

**យ៉េតៈ** ចា៎ស! គេដាក់ ។

**ផៃវ៉ាន់ៈ** ស្រុកសង្កែ?

**យ៉េតៈ** ស្រុកសង្កែដូចគ្នា ។

**ផៃវ៉ាន់ៈ** ឥឡូវគេដាក់អូរដំបង១?

**យ៉េតៈ** ឥឡូវហ្នឹងគេដាក់អូរដំបង១វិញ ខ្ញុំមិនសូវដឹងដែរទេចាស់ទៅខ្ញុំមិនដឹងទៅដល់ខ្ញុំឡប់លិនដែរ ហ្នឹង ខ្ញុំទើបតែងើបដែរ ។

**នៃវ៉ាន់:** ឪពុកម្ដាយរបស់លោកយាយឈ្មោះអីដែរ?

**យើត:** ម្ដាយខ្ញុំ ឪពុកខ្ញុំឈ្មោះឡម, ហើយម៉ែអន ។

**នៃវ៉ាន់:** សព្វថ្ងៃគាត់ខូចអស់ហើយ?

**យើត:** ខូចយូរហើយ តាំងពីយូរណាស់ហើយ ។

**នៃវ៉ាន់:** ខូចតាំងពីមុនខ្មែរក្រហមទៀត?

**យើត:** ចាស! យូរហើយគាត់ ឪខ្មែរក្រហមម៉ោបានម៉ាឆ្នាំអីហើយបានខូច ខ្ញុំនៅឯពោធិសាត់ ណោះពេលគាត់ខូច ។

**នៃវ៉ាន់:** ចុះលោកយាយមានបងប្អូនប៉ុន្មាននាក់ដែរ?

**យើត:** ខ្ញុំបងប្អូនច្រើនប៉ុនខូចអស់ហើយ ៨នាក់ ។

**នៃវ៉ាន់:** ពីដើមម៉ោ៨នាក់?

**យើត:** ដល់ឥឡូវនៅសល់បួននាក់ ស្រីបី ប្រុសមួយ ។

**នៃវ៉ាន់:** សព្វថ្ងៃរស់នៅក្នុងភូមិឃុំជាមួយគ្នា?

**យើត:** នៅនេះ នៅអូរតាគីណោះមួយប្រុស នៅស្រីបីនៅអូរសាឡៅហ្នឹង ។

**នៃវ៉ាន់:** ចុះលោកយាយ អ៊ុត ហឿនហ្នឹងត្រូវម៉េចជាមួយលោកយាយដែរ?

**យើត:** ជីដូនមួយខ្ញុំ ។

**នៃវ៉ាន់:** ត្រូវបងប្អូនជីដូនមួយ, លោកយាយស្គាល់អ៊ុត ហឿនហ្នឹងតាំងពីក្មេងៗជាមួយគ្នាម៉ោ?

**យើត:** ចាស! ចុះបើបងប្អូនជីដូនមួយ នៅតែហ្នឹងហើយ នៅស្រុកជាមួយគ្នាហ្នឹង គ្រាន់តែគាត់ ទៅនៅថ្នល់ ខ្ញុំនៅណេះទៅ ។

**នៃវ៉ាន់:** អ៊ុត ហឿនហ្នឹងគាត់កើតឆ្នាំណាដែរ?

**យើត:** សួរខ្ញុំស្រេចហើយ ។

**នៃវ៉ាន់:** កើតឆ្នាំខ្មែរកើតឆ្នាំអីដែរ?

**យើត:** ឆ្នាំថោះ ។

**នៃវ៉ាន់:** ឆ្នាំថោះ បងលោកយាយអីក៏ប្អូនលោកយាយ?

**យើត:** បងខ្ញុំម៉ាឆ្នាំ ។

**នៃវ៉ាន់:** អញ្ចឹងម៉ោដល់ឥឡូវបើគាត់នៅរស់អាយុបងលោកយាយម៉ាឆ្នាំ?

**យើត:** ចាស! ៦៩ ។

**នៃវ៉ាន់:** ចុះឪពុកម្ដាយហឿនហ្នឹងឈ្មោះអីទៅ?

**យើត:** ឪពុកឈ្មោះតាហម ម្ដាយឈ្មោះសៀន ។

**នៃវ៉ាន់:** សព្វថ្ងៃគាត់ខូចអស់ហើយ?

**យើត:** អូហ៍! យូរណាស់ហើយ ។

**នៃវ៉ាន់:** ស្លាប់តាំងពីមុនខ្មែរក្រហម?

**យើត:** ស្លាប់៧៩នេះ ។

**នៃវ៉ាន់:** ទាំងពីរនាក់ហ្នឹង? ស្លាប់៧៩?

**យើត:** ចាស! ទាំងពីរហ្នឹង ។

**នៃវ៉ាន់:** ហឿនហ្នឹងគាត់មានបងប្អូនប៉ុន្មាននាក់ដែរទាំងអស់?

**យើត:** អ៊ូយ! ឈប់សិនរាប់សិន ផាប់ខ្វះ នៅហឹន, ហឿនហ្នឹង ប្ដីខ្ញុំហ្នឹង, សាម៉ុន, សាមឿន, សាមើត ប៉ុណ្ណឹងតើ ។

**នៃវ៉ាន់:** អញ្ចឹងទាំងអស់៥នាក់ទាំងគាត់?

**យើត:** ចាស! ៥ទាំងខ្មោច ។

**នៃវ៉ាន់:** ហើយប្រុសប៉ុន្មានស្រីប៉ុន្មានដែរ?

**យើត:** ប្រុសពីរហ្នឹងហើយ ឃើញមួយបងឈ្មោះហឹនហ្នឹងប្រុស ស្រីបី ។

**នៃវ៉ាន់:** ស្រីបីនាក់, ចុះហឿនហ្នឹងកូនទីប៉ុន្មាន?

**យើត:** ទី២ ។

**នៃវ៉ាន់:** ចុះបងគាត់ឈ្មោះអីគេ?

**យើត:** ហឹន ស្លាប់បាត់ហើយ ។

**នៃវ៉ាន់:** ហឹន, ប្រុស ស្លាប់ជំនាន់ណា?

**យើត:** មើលផាប់ ទើបតែផាប់នេះដែរ ។

**នៃវ៉ាន់:** ទី២បានហឿនហ្នឹង?

**យើត:** ចាស! បានសាម៉ុនទីបី សាមឿនទីបួន ។

**នៃវ៉ាន់:** សាម៉ុនហ្នឹងស្រីអីប្រុស?

**យ៉ើតៈ** ស្រី ៗ

**ឆៃរ៉ាន់ៈ** សព្វថ្ងៃនៅរស់ទេ?

**យ៉ើតៈ** នៅ ៗ សាមឿនស្រីដែរ រួចសាមើតពៅគេ ៗ

**ឆៃរ៉ាន់ៈ** រស់នៅសព្វថ្ងៃនៅសល់តែស្រីៗ?

**យ៉ើតៈ** ចា៎ស!

**ឆៃរ៉ាន់ៈ** ហើយសាមើត?

**យ៉ើតៈ** សាមើតស្រីដែរ ពៅគេហ្នឹង ប៉ុណ្ណឹងឯង៥ហ្នឹង ៗ

**ឆៃរ៉ាន់ៈ** ចុះលោកយាយហឿនហ្នឹងកាលពីក្មេងៗដូចថាគាត់ធ្លាប់បានរៀន ធ្លាប់បានបួសអីដែរអត់ទេ?

**យ៉ើតៈ** គេបួសយូរណាស់ បួសឡើងមិនហ៊ានទះមូសហើយ ៗ

**ឆៃរ៉ាន់ៈ** បួសឡើងលែងហ៊ានសម្លាប់មនុស្ស?

**យ៉ើតៈ** អត់ទេ ភ្នុំ ឲ្យខាំតាមចិត្តភ្នុំ ដល់អញ្ចឹងគេចោទទេបានទៅអញ្ចឹងនោះ កុំអីគ្នារកតែអាយុទេ គេចោទមនុស្សត្រង់ហ្នឹងហើយ ៗ

**ឆៃរ៉ាន់ៈ** បួសនៅវត្តណាដែរ?

**យ៉ើតៈ** មុនដំបូងវត្តសង្កែក្នុងបាត់ដំបង វត្តសង្កែរួចបានវត្តចែងវង្សី នៅត្រឹមវត្តចែងហ្នឹងបង្រៀន គេហ្នឹង ដល់សឹកទៅអក្ខរកម្មអីហ្នឹង គាត់បួសយូរណាស់ ៗ

**ឆៃរ៉ាន់ៈ** ម៉េាបួសនៅវត្តចែងនេះទៀត?

**យ៉ើតៈ** បួសនៅវត្តសង្កែក្នុងណោះ រួចបានម៉េានេះ ៗ

**ឆៃរ៉ាន់ៈ** គាត់បួសបានប៉ុន្មានវស្សាដែរយាយ?

**យ៉ើតៈ** បួសដឹកបាន៥វស្សា ហើយនេនខ្ញុំមិនដឹងទេ ដឹងតែបួសដឹកហ្នឹង៥វស្សា ៗ

**ឆៃរ៉ាន់ៈ** បួសដឹកហ្នឹងបួសម៉េច?

**យ៉ើតៈ** ភិក្ខុ ៗ

**ឆៃរ៉ាន់ៈ** សរុបទៅប្រហែលជា១០វស្សាអីដែរអត់?

**យ៉ើតៈ** មិនដឹងទេ ខ្ញុំមិនដឹងទេ នេនមិនដឹងប៉ុន្មានទេ ដឹងតែដឹកហ្មង ដឹកដឹងតែប្រាំវស្សាហ្មង បួសនេនខ្ញុំអត់ដឹងទេ ៗ

**ផៃរ៉ាន់:** គាត់អត់ដែលរៀនទេ មានតែបានតែបួសហ្នឹងទេ?

**យើគ:** បានបួសហ្នឹង គាត់រៀនតើ វត្តសង្កែក្នុងណោះ គាត់រៀនហ្នឹង ។

**ផៃរ៉ាន់:** បួសបណ្ដើររៀនបណ្ដើរ?

**យើគ:** បួសបណ្ដើររៀនបណ្ដើរ ដល់ពេលហ្នឹងគាត់ឈប់ពីណោះគាត់ម៉ោស្រុកនេះវិញណា៎ គាត់ម៉ោម៉ែឪគាត់វិញទៅ គាត់បង្រៀនវត្តចែង កូនក្មេងនៅនឹងវត្តហ្នឹង បង្រៀនហ្នឹងរួចទៅបាន ម៉ោបង្រៀនអក្ខរកម្ម រួចហើយគាត់ធ្វើស្រែបន្តបណ្ដើរ ។

**ផៃរ៉ាន់:** ចុះអាពេលគាត់ម៉ោវត្តចែងហ្នឹងគាត់លែងបួសហើយ អីក៏នៅបួសដដែល?

**យើគ:** បួស ។

**ផៃរ៉ាន់:** បួសបាន៥វស្សានៅវត្តចែងនេះ?

**យើគ:** ចា៎ស! ប៉ុន្តែនេនខ្ញុំមិនដឹងទេ អញ្ចឹងហើយបានថា មូសអីដល់ភ្នំអញ្ចេះហើយ មានអីទៀតកាន់សីលដល់អញ្ចឹងហើយបានថា ។

**ផៃរ៉ាន់:** ចុះហេតុអីបានគាត់សឹកពីបួសយាយ?

**យើគ:** ចុះគាត់នេះហើយ គាត់អាយុច្រើនហើយមានតែសឹកធ្វើស្រែម្ដង ចង់បានប្រពន្ធ ។

**ផៃរ៉ាន់:** ពេលគាត់សឹកហ្នឹងតាមលោកយាយចាំឆ្នាំណាដែរ?

**យើគ:** អត់ចាំទេ ។

**ផៃរ៉ាន់:** មុនរដ្ឋប្រហារអីក៏ក្រោយរដ្ឋប្រហារ?

**យើគ:** អូហ៍! យូរណាស់ អាយុឡើងច្រើនហើយ ។

**ផៃរ៉ាន់:** លោកយាយការហើយប៉ុន្មានឆ្នាំបានមានកូន?

**យើគ:** ប៉ុន្មានទេ ម៉ាឆ្នាំមិនដឹង ថាម៉ាឆ្នាំចុះ ។

**ផៃរ៉ាន់:** ចុះកូនបងគេហ្នឹងអាយុប៉ុន្មានហើយ?

**យើគ:** ៤១ហើយ ឆ្នាំមមីមិនដឹងប៉ុន្មានទេ ៤១ហើយ ។

**ផៃរ៉ាន់:** លោកយាយការបានម៉ាឆ្នាំបានមានកូន?

**យើគ:** ចា៎ស!

**ផៃរ៉ាន់:** អញ្ចឹងការខ្ទង់៦៤, ៦៥អីហ្នឹង?

**យើគ:** មិនដឹង ការតាំងពី២៧ ។

**ផៃវ៉ាន់:** គាត់សឹកពីបួសភ្លាមការភ្លាមអីម៉េច?

**យើត:** ការតាំងពី២៧ម្ភៃ បានយូរដែរហ្នឹងណា៎ មិនដឹង ។

**ផៃវ៉ាន់:**

លោកយាយដល់ពេលគាត់ធ្វើស្រែចំការហើយបានម៉ាឆ្នាំហើយគាត់រៀបការជាមួយលោក យាយ?

**យើត:** ចា៎ស!

**ផៃវ៉ាន់:** ដូចថាគាត់រៀបការជាមួយលោកយាយហ្នឹងដោយសារឪពុកម្ដាយភ្ជង់ផ្ដើមឲ្យការ ឬក៏គាត់មានចិត្តខ្ជួនគាត់?

**យើត:** គាត់មានចិត្តខ្ជួនគាត់ ។

**ផៃវ៉ាន់:** ចុះពេលរៀបការហើយលោកយាយគាត់អីហ្នឹងប្រកបមុខរបបរកស៊ីអីទៅ?

**យើត:** ខ្ញុំធ្វើស្រែធ្វើចំការ ប៉ុនឥឡូវចំការអស់ហើយហ្នឹង បាននៅបន្តិច ។

**ផៃវ៉ាន់:** ធ្វើស្រែចំការធម្មតា?

**យើត:** ចា៎ស! ធម្មតា ហើយដល់នេះគេចោទតើបានទៅអញ្ចឹងនោះ ។

**ផៃវ៉ាន់:** លោកយាយការបានប៉ុន្មានឆ្នាំបានគេចោទថាគាត់ខ្មែរក្រហមហ្នឹង?

**យើត:** អូហ៍! យូរណាស់ បានកូនបាននេះហើយ កូនទី២ហើយទើបតែបានបីខែទេគេចោទហ្នឹង ខ្ញុំកើតបានបីខែទាស់សសៃចង់ស្លាប់ដែរ តែប៉ុន្មានលើកអញ្ចឹងដែរ ។

**ផៃវ៉ាន់:** លោកយាយគេចោទថាគាត់ខ្មែរក្រហមហ្នឹង កាលហ្នឹងតាមលោកយាយចាំគេរដ្ឋប្រហារទម្លាក់សម្ដេចនៅ?

**យើត:** ទម្លាក់ហ្នឹងហើយបានរតេងរតោង ។

**ផៃវ៉ាន់:** ពេលគេទម្លាក់សម្ដេចហ្នឹងគេថាគាត់ហ្នឹងចូលខ្មែរក្រហម?

**យើត:** ចា៎ស! ចុះសម្ដេចថាកូនចៅចូលម៉ាគី មិនចូលម៉ាគីប្រោកមែន ។

**ផៃវ៉ាន់:** ហើយគាត់ចូលទេ?

**យើត:** គាត់មានចូលណា៎ គេកំពុងតែធ្វើស្រែបោះកណ្ដាប់អញ្ចឹងស្រាប់តែគេដេញបាញ់ គេឲ្យអ្នកក្រហ្នឹងធ្វើធំម្ដងណា៎ ម្ភោះហើយម៉ោដេញអាអ្នកស្រែហ្នឹងទៅ ម៉ោចោទហ្នឹងរត់អូរស្រឡៅ ចង់ទាំងអស់ ប៉ុនគេបេះតែលុះទៅ

លោកសុភីចេះតែលុះម៉ោៗ បានម៉ោនៅវិញ ប្ដីខ្ញុំៗទៅ ណា ខ្ញុំបីខែខ្ញុំទាស់សសៃសីងតែស្លាប់ខ្ញុំគ្មានទៅយកឯណា ដល់ពេលទៅយកវាកើតចេះតែទៅៗ គេថាកាត់ក្បាត់ដល់អញ្ចឹងអត់ហ៊ានម៉ោទេ ។

**ផៃវ៉ាន់:** អញ្ចឹងខាងណាម៉ោចោទថាគាត់ខ្មែរក្រហម?

**យើគះ:** ងាប់បាត់អស់ហើយ មិនដឹងខាងណាខាងណៃទេខ្ញុំនោះ តែសួរខ្ញុំអញ្ចឹងស្រេចលែងដឹងបាត់ មិនដឹងលន់ ណុល មិនដឹងជាស្អីផង ពូថាចូលម៉ាគីនោះក៏គេគាត់គោយអស់ទៅមិនដឹង កាលហ្នឹងដឹងតែចូលម៉ាគីហ្នឹងហើយ ទៅបាត់អស់ទៅ ប្ដីខ្ញុំកុំតែគេចោទធ្វើស្រែដល់សព្វថ្ងៃ ។

**ផៃវ៉ាន់:** ដល់ពេលគេចោទថាគាត់ចូលខ្មែរក្រហមអញ្ចឹងគាត់រត់ចូលព្រៃបណ្ដោយ?

**យើគះ:** គាត់មិនចូលទេ គាត់នៅត្រើយណោះ ។

**ផៃវ៉ាន់:** នៅត្រើយណា?

**យើគះ:** ត្រើយឆ្ងាយណាស់ ប៉ុនគាត់មិនហ៊ានចូលផ្ទះ ហើយគាត់នៅយូរៗទៅបែបមានខ្មែរក្រហម ម៉ោស្ទាក់អីយកទៅខ្ញុំមិនដឹងដែរណា៎ ហ្នឹងខ្ញុំនៅកូនខ្ចីទេកាលហ្នឹងនោះ ។

**ផៃវ៉ាន់:** អូហ៍! អាពេលគេចោទហ្នឹងគាត់រត់ទៅលោកយាយអត់មានដឹងដំណឹងអីពីគាត់ទេ?

**យើគះ:** រត់តែម៉ារស់ទេ ដឹងតែនៅត្រើយខាងហ្នឹង ។

**ផៃវ៉ាន់:** ត្រើយខាងហ្នឹងនៅក្នុងភូមិឃុំស្រុកអីដែរ?

**យើគះ:** អូហ៍! ព្រៃណោះ នេះត្រង់ណោះដែរ ផ្លូវស្រឡះអស់ហើយ ពីដើមព្រៃ អូរស្រឡៅ ខាងលិចវាំងគេសីហ្នឹងណា៎ ពីដើមព្រៃស្ដុកអូរដែរហ្នឹង ។

**ផៃវ៉ាន់:** អញ្ចឹងដោយសារគេចោទអញ្ចឹងគាត់រត់ចូលព្រៃ?

**យើគះ:** ចា៎ស!

**ផៃវ៉ាន់:** ដល់ពេលអត់ហ៊ានចូលម៉ោផ្ទះអញ្ចឹងគាត់ចូលខ្មែរក្រហមទៅ?

**យើគះ:** ទេ មិនដឹងចូលស្អី មិនដឹងគេម៉ោអីក៏មិនដឹងដែរហ្នឹងណា៎ ខ្ញុំមិនដឹងទេ ខ្ញុំនៅតែផ្ទះនោះ ។

**ផៃវ៉ាន់:** ចុះគាត់រត់ទៅលាក់ខ្លួនក្នុងព្រៃហ្នឹងរយៈពេលប៉ុន្មានទៅ បានម៉ោជួបលោកយាយវិញ?

**យើគះ:** ទាល់តែ៧៩ហ្នឹង ៧៩ បើមិនហ៊ានម៉ោបានអីម៉ោ ៧៩ បានម៉ោ ម៉ោបានប៉ុន្មានពាឆ្នាំប៉ុន្មានខែ គេចោទទៅបាត់ទៀតទៅ ខ្ញុំមិនដឹងថាម៉េច

បើខ្ញុំណោះទាស់សសៃសឹងដាច់ខ្យល់ខ្ញុំមិនដឹង ជងវង្វេងអស់ហើយ កំពុងតែពិបាកចិត្តនឹងអញ្ចឹង ទើបតែចូល៧៥បានប៉ុន្មានហ្នឹងហើយ ៣ឆ្នាំប៉ុន្មាន ខ្ញុំមិនដឹងទេ ពិបាកចិត្តចិញ្ចឹមកូនក្រោយទៀត ។

**ឆែវ៉ាន់:** លោកយាយមានដឹងថា ពេលដែលគាត់រត់ចូលព្រៃហ្នឹងហើយក្រោយម៉ោគាត់ចូលបម្រើខ្មែរក្រហមហ្នឹង ដំបូងបំផុតហ្នឹងគេឲ្យគាត់ធ្វើអីទៅ? ដែលគាត់ចូលមុនគេ ពេលដែលគាត់លាក់ខ្លួននៅក្នុងព្រៃហ្នឹងណា៎?

**យ៉ើត:** អត់ដឹង ។

**ឆែវ៉ាន់:** លោកយាយនៅផ្ទះនេះធម្មតា?

**យ៉ើត:** ខ្ញុំនៅតែនេះមើលតែកូនអញ្ចឹង ។

**ឆែវ៉ាន់:** ចុះមានដឹងថា

ពេលដែលគាត់រត់ទៅលាក់ខ្លួននៅព្រៃហ្នឹងគាត់ដែលផ្ញើសំបុត្រអីម៉ោលោក យាយទេ?

**យ៉ើត:** អត់សោះ ។

**ឆែវ៉ាន់:** បាត់ដំណឹង ដល់ឆ្នាំ៧៥ បានដឹងវិញ?

**យ៉ើត:** ចា៎ស! មិនហ៊ានទាក់ទង ទាល់តែចូលម៉ោបណ្ដោយហ្នឹង ដល់៧៥បណ្ដោយហ្នឹង ។

**ឆែវ៉ាន់:** តែពេលដែលគាតរត់ទៅលាក់ខ្លួននៅក្នុងព្រៃហ្នឹង លោកយាយមានដឹងថាគាត់នៅរស់ឬក៏ ម៉េច?

**យ៉ើត:** កាលហ្នឹងនោះ មិនដែលគេនិយាយអីផង ចេះតែស្ងាត់ស្ងៀមៗ ដល់៧៥ឃើញម៉ោទៅ ម៉ោជាមួយកងទ័ពកងអីទៅ ខ្ញុំមិនដឹងដែរ ម៉ោជួបគ្នានៅបាត់ដំបងហ្នឹងទៅរត់ដែរ ខ្ញុំរត់ទៅ ហ្នឹងដែរ រត់ដែរជួបនៅហ្នឹងបណ្ដោយទៅ ពេលហ្នឹងស្រុកអូរស្រឡៅរត់ទាំងអស់ហ្នឹង ។

**ឆែវ៉ាន់:** ពេលឆ្នាំ៧៥គាត់ចូលម៉ោភូមិឃុំនេះម៉ោរកលោកយាយវិញ?

**យ៉ើត:** អត់ជួបនេះទេ ណោះរត់អស់ហើយខ្លាចគ្រាប់នោះរត់ចូលស្រុកអស់ហើយ ។

**ឆែវ៉ាន់:** ទៅជួបនៅណាទៅ?

**យ៉ើត:** ទៅជួបនៅកន្លែងគុយសេ ។

**ឆែវ៉ាន់:** នៅកន្លែងណាទៅ?

**យើគៈ** កន្លែងគុយសេ ផ្សារដែលចំណាំពួកទាហាននៅនោះ ខាងលិចផ្សារលើណោះ នៅតែហ្នឹង រត់តែទាំងអស់ហ្នឹង អ្នកអូរស្រឡៅ ។

**នៃវ៉ាន់:** អូហ៎! គាត់ទៅរកដល់ហ្នឹងហ៎?

**យើគៈ** គាត់ចូលទៅដល់ហ្នឹង កងទ័ពចូលទៅដល់ហ្នឹង មិនដឹងកងទ័ពអីៗទេ ខ្ញុំមិនដឹងទេ ចូលទៅៗ បានជួបៗហ្នឹងមិនឆាយបានជួបដែរទេ គាត់សើរើក្នុងហ្នឹងដែរហ្នឹងខ្លាចឃើញដែរហ្នឹង ថាខ្ញុំ ឆាប់អស់ហើយហ្នឹង ព្រោះអីគ្រាប់នៅតំបន់ផ្សេងណា៎ ពេញធឹងនេះហើយ នេះមានណា នៅ រត់អស់ ។

**នៃវ៉ាន់:**

អញ្ចឹងនៅតាមស្រុកភូមិនេះប្រជាជននៅខាងអូរស្រឡៅនេះចេញពីភូមិឃុំនៅឆ្នាំណាទៅ?

**យើគៈ** ចេញកាលរត់ហ្នឹងហ៎ ។

**នៃវ៉ាន់:** ពេលដែលឆ្នាំដែលគាត់ចូលលាក់ខ្លួនហ្នឹង លោកយាយនៅខាងស្រុកភូមិនេះដដែលទេ?

**យើគៈ** ចា៎ស!

**នៃវ៉ាន់:** ដល់ពេល៧៥បានជម្លៀសចេញ?

**យើគៈ** ៧៥គ្មានណាជម្លៀសទេ គេបាញ់យើងរត់ខ្លួនយើងទៅ គ្រាប់សំបើមណាស់ រត់ទាំងអស់គ្នា ។

**នៃវ៉ាន់:** រត់ទៅខាងណាវិញ?

**យើគៈ** រត់ទៅខាង ទៅផ្សារណោះ ទីក្រុងណោះ ។

**នៃវ៉ាន់:** ចូលបាត់ដំបងហ្នឹង?

**យើគៈ** ចា៎ស! រត់ទៅទាំងអស់គ្នាហ្នឹង ។

**នៃវ៉ាន់:** រត់ទៅដល់ហ្នឹងបានជួបគ្នាវិញ?

**យើគៈ** ចា៎ស! ទៅហ្នឹងបាននេះ បានព្រឹកឡើងបានពួកគេសើរើរកខ្ញុំហ្នឹងណា៎ គេខ្លាចខ្ញុំឆាប់បាត់ហើយ ព្រោះគ្រាប់ណាស់ រត់នឹងគ្រាប់ទេ មែនគេដេញទេ អានេះរត់នឹងគ្រាប់តែហ្នង ។

**ផៃរ៉ាន់:** ចុះពេលលោកយាយបានជួបគ្នាជាមួយគាត់នៅបាត់ដំបងហ្នឹង ពេលហ្នឹងលោកយាយមានដឹងថាគាត់កាន់ខាងតួនាទីអីដែរអត់?

**យ៉េត:** អត់ មិនបានដេញដោលទេ ។

**ផៃរ៉ាន់:** តែដឹងថាគាត់ចូលខាងខ្មែរក្រហមហើយ?

**យ៉េត:** ចុះបើគាត់ទៅហើយ មិនដឹងគាត់ចូលអីបើឃើញតែអញ្ចឹង កងទ័ពម៉ោឃើញមានអញ្ចឹង ដល់ពេលនេះឃើញគាត់ដឹកអីវ៉ាន់ចែកបងប្អូនហ្នឹង ។

**ផៃរ៉ាន់:** ៧៥ហ្នឹង?

**យ៉េត:** ចា៎ស!

**ផៃរ៉ាន់:** ពេលចូលដល់ភ្លាមហ្នឹង?

**យ៉េត:** ចា៎ស! ចូលដល់សួរថាទៅណា ថាដឹកនេះទៅ ។

**ផៃរ៉ាន់:** ដឹកចែកបងប្អូន?

**យ៉េត:** ដឹកចែកបងប្អូនណាអត់អីចឹង ឃើញតែអញ្ចឹង ទៅមោងក៏អញ្ចឹង ដល់នេះគេឲ្យគាត់ទៅមោង ណា៎ ឃើញចែកតែគេអញ្ចឹង គាត់អត់មានថានេះសោះ ឃើញថាយករបស់គេអត់សោះ ឃើញតែអញ្ចឹងឯង ។

**ផៃរ៉ាន់:** ដំបូងឡើងគាត់នៅខាងភស្តុភារអីក៏យ៉ាងម៉េច?

**យ៉េត:** មិនដឹង ខ្ញុំមិនបានសួរទេ ខ្ញុំមិនហ៊ានសួរទេ ខ្ញុំខ្លាចដែរនោះ ខ្លាចនឹងពួកហ្នឹងដែរ ចុះពួកគេកងទ័ព ខ្ញុំ១៧មេសានោះ ខ្ញុំទៅណាខ្ញុំ នៅតែនេះ ហើយចិញ្ចឹមតែកូនអញ្ចឹងឯង ។

**ផៃរ៉ាន់:** ពេល៧៥ភ្លាមលោកយាយជួបគាត់នៅបាត់ដំបងហ្នឹងក៏គាត់ចែកឲ្យអ្នកស្រុកអីដែរ?

**យ៉េត:** តែអញ្ចឹងឯង ដើរចែកតែគេហ្នឹង ធ្វើស្រែធ្វើអីដើរចែកតែគេហ្នឹង មិនដែលបង្អត់ប្រជាជនផងហ្នឹង បានគេអាណិតគាត់ ឃើញរស់ ខ្ញុំនឹកឃើញថាធ្វើត្រង់ងាប់រហ័ស ។

**ផៃរ៉ាន់:** អញ្ចឹងគាត់នៅបាត់ដំបងហ្នឹង?

**យ៉េត:** នៅបានតែប៉ុន្មានខែទេហ្នឹងនោះ ទៅមោងបានទៅពោធិសាត់បាននៅយូរ ទៅហ្នឹងណា៎ ។

**ផៃរ៉ាន់:** បានប្រហែលប៉ុន្មានខែដែរ?

**យ៉ើត:** ប៉ុន្មានទេ ប្រហែលម៉ាខែដឹង បាត់ដំបងនោះ ដល់មោងបានបីខែមិនដឹង ដល់ទៅពោធិសាត់បានរាប់ឆ្នាំ បានប៉ុន្មានឆ្នាំហ្នឹង បានត្រឡប់ម៉ោបាត់ដំបងវិញ ទៅម៉ោៗតែហ្នឹង នៅពោធិសាត់បានយូរបន្តិច ។

**ឆៃវ៉ាន់:** ទៅពោធិសាត់ហ្នឹងនៅស្រុកណាភូមិណាដែរ?

**យ៉ើត:** ចា៎ស! នៅវ៉ាៗពោធិសាត់ហ្នឹង ពេទ្យគេនៅកើត ខ្ញុំនៅរថភ្លើងហ្នឹង ខ្ញុំដាំបាយហ្នឹងហើយ គាត់នៅរទេះភ្លើងអញ្ចឹង ។

**ឆៃវ៉ាន់:** ពេលទៅមោងក៏គាត់ខាងបែកផ្សាវ៉ាន់ឲ្យប្រជាជនដែរ?

**យ៉ើត:** ចា៎ស! គាត់ធ្វើតែអញ្ចឹង ។

**ឆៃវ៉ាន់:** បែកស្រូវបែកអង្ករហ្នឹងហេ៎?

**យ៉ើត:** ចា៎ស!

**ឆៃវ៉ាន់:** ដល់ពេលទៅដល់ពោធិសាត់គាត់ធ្វើខាងរទេះភ្លើងម្តង?

**យ៉ើត:** ខាងឡើងរទេះភ្លើង ។

**ឆៃវ៉ាន់:** ប្រធានគេអីក៏ម៉េច?

**យ៉ើត:** ខ្ញុំមិនដឹងធ្វើអីទេ ហ្នឹងទាល់តែសួរអ្នកនេះបានគេដឹងទៀត ។

**ឆៃវ៉ាន់:** នៅមោងបានបីខែបានទៅពោធិសាត់?

**យ៉ើត:** ចា៎ស! នៅពោធិសាត់បានយូរ ។

**ឆៃវ៉ាន់:** ពេលហ្នឹងចុង៧៥អីហ្នឹងបានទៅពោធិសាត់ហ្នឹង?

**យ៉ើត:** ដល់ម៉ោណោះខែ៧ ៧៧ ។

**ឆៃវ៉ាន់:** ម៉ោបាត់ដំបងវិញហ្នឹងហេ៎?

**យ៉ើត:** ចា៎ស! ខែ៧ហ្នឹងឯង កូនខ្ញុំកាលហ្នឹងកើតអានេះបាន១៩ថ្ងៃ ជិះរទេះភ្លើងម៉ោរលាក់ទាស់ហ្នឹង ។

**ឆៃវ៉ាន់:** យាយពេលគាត់ទៅដល់ពោធិសាត់ហ្នឹង បានគាត់ឡើងធ្វើរទេះភ្លើងហ្នឹងតាមលោកយាយ ចាំ គាត់ប្រធាន ឬក៏គ្រាន់តែកូនចៅគេទេ?

**យ៉ើត:** នេះដឹង គាត់ប្រធានបើករទេះភ្លើងហ្នឹងដឹង គ្រាន់ឲ្យមានអ្នកបើកផ្សេង គាត់មិនបើកទេ ប៉ុនគាត់អង្គុយនៅទីផក្បាលហ្នឹងដែរ ប៉ុនខ្ញុំមិនដឹងគាត់ធ្វើអីទេ ។

**ណៃរ៉ាន់:** ដូចថាខាងបើករទេះភ្លើងហ្នឹង ការងារគាត់បើកតែរទេះភ្លើងហ្នឹងអីក៏មានអីផ្សេងទៀត?

**យ៉េត:** ធ្វើស្រែហ្នឹង ឲ្យកូនចៅចិញ្ចឹមទា គ្រាន់ឲ្យប្រជាជនហូបកុំឲ្យវាអត់បាយអត់ទឹក ហើយស្រូវក៏ល្អផលហ្នឹងក៏បាន សួរអ្នកពោធិ៍សាត់ក៏ដឹងដែរ បើថាឈ្មោះអញ្ចឹងនោះ គេដឹងតែទាំងអស់ហ្នឹង ខ្លាចអ្នកណាងាប់រស់អីខ្ញុំមិនដឹងទេណា៎ឥឡូវហ្នឹង ខ្ញុំមិនដែលទៅ អ្នកបាត់ដំបងនេះក៏ដឹងដែរនៀក ។

**ណៃរ៉ាន់:** ពោធិ៍សាត់ហ្នឹងពេលដែលគាត់ដូរទៅហ្នឹង

គាត់នៅក្នុងតំបន់លេខប៉ុន្មានដែរខាងពោធិ៍សាត់?

**យ៉េត:** មិនដឹង ខាងរទេះភ្លើងមិនដឹងអី គាត់ទៅដឹកនេះនោះ

ដឹកអូសដឹកអីដាក់រទេះភ្លើងក៏គាត់ទៅ គាត់ទៅមើលណា៎ជួយ ត្រូវលើកអីគាត់ជួយ ។

**ណៃរ៉ាន់:** រទេះភ្លើងហ្នឹងគេបើករាល់ថ្ងៃហ៎?

**យ៉េត:** កាលហ្នឹងហ៎! បើករាល់តែថ្ងៃទៅម៉ោ ។

**ណៃរ៉ាន់:** ដឹកអីខ្លះទៅ ?

**យ៉េត:** មិនដឹងដឹកអីទេ ខ្ញុំមិនដឹងទេ ខ្ញុំដាំបាយ មិនដែលដឹង កន្លែងគេផ្សេងទៅមើលគេម៉េចកើតនៅផ្ទះបានផ្ទះឆ្នាំង ហើយនិងដាំបាយ ហើយនិងស្ល ។

**ណៃរ៉ាន់:** តែពេលទៅអញ្ចឹងល្ងាចឡើងយើងត្រឡប់ម៉ោផ្ទះធម្មតា

អីក៏យើងនៅដេកតាមផ្លូវតាមអី?

**យ៉េត:** អត់ទេ ទៅត្រឹមអីគេហៅអារ៉ាញ់ហ៎ ។

**ណៃរ៉ាន់:** អារ៉ាញ់ស្រុកថៃហ្នឹងហ៎?

**យ៉េត:** ចា៎ស! រទេះភ្លើងទៅដល់ហ្នឹង ទៅដលហ្នឹងដែរតើ

បកពីហ្នឹងម៉ោទៅពោធិ៍សាត់ដដែលទៅ

ពេលគេត្រូវការអូសអីគាត់នាំគេទៅយកអូសអីដាក់លើហ្នឹងយកម៉ោឲ្យគេណា៎

ធ្វើជាប់រហូត អញ្ចឹង ។

**ណៃរ៉ាន់:** តាមលោកយាយដឹងរទេះភ្លើងហ្នឹងសម្រាប់ដឹកអីៗខ្លះទៅ ដឹកមនុស្ស?

**យ៉េត:** បើនិយាយពីរឿងដឹកមនុស្សវិញ មានតែដឹកកូនក្មេងយកទៅ ហ្នឹងនៅផ្សារទេណា៎ ។

**ណៃរ៉ាន់:** ផ្សារណា?

**យើត:** ផ្សាបាត់ដំបងនេះណា៎ ដឹកយកទៅចំការចេកណោះ ដាក់រទេះភ្លើងទៅដាក់កូនចៅទៅស្ទូង យប់នោះ កាលហ្នឹងបើថាអត់ណាស់នោះ បានស្រូវហ្នឹងហើយដែលចិញ្ចឹមរស់នោះ ពីដើម ហូបបបរហូបអីហ្នឹង ដល់ខាងហ្នឹងទៅ គេដាក់បាយអីម្តងពេលធ្វើការខ្លាំង ធ្វើការរឿងអូស ហ្នឹងហេ៎ កាប់អូសកាប់អី ដឹកជញ្ជូនឲ្យគេហ្នឹងប្រជាជនហ្នឹង គាត់គ្មានទៅណាទៀតនៅតែ ហ្នឹង ។

**ផៃរ៉ាន់:** អញ្ចឹងគាត់នៅពោធិសាត់ហ្នឹងតាមលោកយាយស្មានប្រហែលជាប៉ុន្មានឆ្នាំណាដែរ?

**យើត:** មើលខ្ញុំថាម៉ោខែ៧ ៧៧មិនដឹងប៉ុន្មានឆ្នាំ អាណឹងបើបីឆ្នាំជាងរត់ទៀត បើថានៅមោងបាន តិចទេណា៎ បើនៅបាត់ដំបងបានប្រហែលម៉ាខែណោះ មោងបែបបានបីខែ ពោធិសាត់ កាលម៉ាហឹកហ្នឹងវាយ៉ាប់ៗអ្នកមុន យ៉ាប់ណាស់ យ៉ាប់រឿងហូប វាអត់អញ្ចឹង ប្រជាជន អញ្ចឹងវាអត់ វេទនា ដល់តានេះទៅ គេភ័យគ្រប់គ្នាថា តាម៉ូមម៉ោទៀតបែបដូចមុនហើយ លើសមុនទៀត មុខកាច គេហៅតាម៉ូមៗណា៎ ។

**ផៃរ៉ាន់:** អូហ៍! គេហៅម៉ូមហេ៎?

**យើត:** ចា៎ស!

**ផៃរ៉ាន់:** គាត់មានពុកមាត់ពេញ?

**យើត:** ចា៎ស! ជំនាន់អាពតគេហៅតាម៉ូមហ្នឹងបានពួកអ្នកស្រុកហ្នឹងគេភ័យ គេថាមុខតែកាចលើស មុនណា៎ ព្រោះមុនៗវាល្បីល្បាញអស់ហើយណា៎ ហើយគាត់ទៅស្ទូតមានអី អ្នកទាស់ សសៃខ្ញុំហើយខ្ញុំត្រាំស្រាត្រាំទុកឲ្យអ្នកទាស់សសៃហ្នឹងណា៎ ចុះធ្វើការធ្ងន់ឲ្យកាប់អូស ហើយ អ្នកក្រមុំរៀង៧-៨ខែអត់ឲ្យរកថ្នាំឲ្យគ្នាទេ ប្តីខ្ញុំទៅរកថ្នាំឲ្យ កូនគេកូនឯងអាណិតណាស់ ក្បាលជង្គង់អញ្ចេះណោះ វេទនា ដល់នេះខ្ញុំត្រាំស្រាអីឲ្យផឹក ប្តីខ្ញុំដើររកអង្គុញដើររកអីឲ្យ ណា៎ បេះតែដើរសុំគេយកម៉ោកូនចៅ កូនចៅសុទ្ធតែក្រមុំៗទាស់ អត់មានខែនោះ រាំងនោះ ធ្វើការធ្ងន់ អារអូសនោះ ខាងរទេះភ្លើងអារអូសហើយដាក់រទេះភ្លើងនោះ ដល់នេះទៅបាន

គ្នាក្រមុំនោះម្ដាយអរណាស់ ជួយកូនខ្ញុំម៉ោពីណោះផង កាលហ្នឹងនៅផ្សេងគ្នា មួយហៅខ្ញុំ មិនដឹងហៅអីទេមិនដឹងទេ ។

**ផៃវ៉ាន់:** មួយពាយ័ព្យមួយអី?

**យ៉េតៈ** គេហៅអី មួយនៅតំបន់នេះតំបន់នោះអញ្ចឹង តែវេទនាណាស់ តែយកម៉ោគាត់កត់ឈ្មោះ ឲ្យយកកូនម៉ោ ទុកនៅការដ្ឋានហ្នឹង ទុកនៅកន្លែងបាយនិងខ្ញុំហ្នឹងទៅក៏ប្ដីខ្ញុំទៅរកអន្លុយរកអី ដាក់ទៅត្រាំឲ្យកូនចៅហ្នឹងបានម៉ោ ដល់ម៉ោគ្នាឲ្យនៅកន្លែងបាយហ្នឹងទៅ អត់ឲ្យទៅធ្វើអីទេ គ្រាន់តែជួយចិតបន្លែដែរ បើមុននោះទៅអារអូសនោះ អ្នកមុនទេណោះ ប្ដីខ្ញុំទើបតែទៅក្រោយទេ ។

**ផៃវ៉ាន់:** អ្នកមុនគេយកទៅណាទៅ?

**យ៉េតៈ** អ្នកមុនគេមានយកទៅណា ដូចថាប្រើគោមិនឲ្យស៊ីស្មៅអញ្ចឹងណា៎ ហ្នឹងរបៀបអញ្ចឹងប្រើ តែគោចេះតែប្រើ ស្មៅមិនឲ្យស៊ីចេះតែអញ្ចឹងឯង ។

**ផៃវ៉ាន់:** អ្នកមុនគេផ្លាស់ចេញទៅបានចូលគ្រួសារលោកយាយវិញ?

**យ៉េតៈ** ចា៎ស! មិនដឹងផ្លាស់មិនដឹងធ្លាក់ ខ្ញុំមិនដឹងដែរ ខ្ញុំទើបតែទៅដែរហ្នឹង ។

**ផៃវ៉ាន់:** ចុះកាលដែលគេបញ្ជូនគាត់ទៅពោធិសាត់ ទៅខាងផ្នែករទេះភ្លើងហ្នឹងដូចថា ខាងណាដែលចាត់តាំងឲ្យគាត់ទៅហ្នឹង? ពីណាគេដែលចាត់តាំងឲ្យគាត់ទៅពោធិសាត់ហ្នឹង?

**យ៉េតៈ** មិនដឹងទេ ធំលើហ្នឹង ខ្ញុំមិនដឹងដែរ មានពីលើគាត់ទៀត លើពីរបីទៀតណោះ ។

**ផៃវ៉ាន់:** ស្គាល់ឈ្មោះទេ?

**យ៉េតៈ** អូហ៍! ខ្ញុំអត់ស្គាល់ទេ ខ្ញុំ១៧មេសាដែលស្គាល់ខ្ញុំទៅក្រោយទើបតែជួបគ្នាប្ដីដែរហ្នឹង ។

**ផៃវ៉ាន់:** អញ្ចឹងពេលដែលគាត់ទៅពោធិសាត់ហ្នឹង ខាងរទេះភ្លើងហ្នឹងក៏នៅតែរកម្ហូបរកអីឲ្យប្រជាជនដែរ?

**យ៉េតៈ** ចុះទៅស្លូងជាមួយគេទាំងយប់ទាំងថ្ងៃជាមួយគេហ្នឹង គាត់ប្រឡូកឡើងផុងត្រឹម១ណោះខោ អាខ្មៅហ្នឹងជ្រៀករយៀកហ្នឹង ខ្ញុំប្រាប់ទៅខ្ញុំមិនករទេ និយាយចាំងអំបែងក្បាលហ្នឹងវេទនាណាស់ណា៎ ។

**ផៃវ៉ាន់:** ប៉ុនកាលហ្នឹងពេលគាត់ទៅកាន់នៅកន្លែងហ្នឹង ដូចថាប្រជាជនបានហូបច្រើនជាងមុន?

**យ៉េតៈ** ច្រើនហើយបានគេអរណោះ គេអបអរសាទរ គេយំ ហើយគេផ្លាស់ម៉ោបាត់ដំបងវិញ ជិតដល់ហើយណា៎ ជិតដល់អាពេលផ្លាស់រត់ហ្នឹងហើយ ម៉ោដល់បានប៉ុន្មានឆ្នាំហ្នឹង ណោះមិន ដឹងបានប៉ុន្មានទេខ្ញុំភ្លេចហើយ ដល់ម៉ោហ្នឹងពួកហ្នឹងយំ គាត់កុហក់គេថាធ្លាក់នោះ គេយំអា ណិតគាត់នោះ បានខ្ញុំនឹកគួចចិត្តអីអាណិតស្អី ត្រង់នោះងាប់មុនគេ គេរៀបរក់គេរស់នោះ នឹកឃើញអញ្ចឹងដែរ គួចចិត្តអញ្ចឹងតើ ។

**ឆៃរ៉ាន់ៈ** នឹកឃើញថាម៉េច?

**យ៉េតៈ** នឹកឃើញថា ត្រង់ៗងាប់មុនគេនោះ ហើយអាណិតប្រជាជនៗខំឲ្យបន់ឲ្យបានរស់ គាឲ្យបានរស់ ខ្ញុំឃើញនឹងភ្នែកណា៎ ខ្ញុំក៏យំដែរ យំទាំងអស់គ្នា ។

**ឆៃរ៉ាន់ៈ** អាពេលដែលគេផ្លាស់ម៉ោបាត់ដំបងវិញហ្នឹងហ៎?

**យ៉េតៈ** ហ្នឹងហើយផ្លាស់ទេ ប៉ុនគាត់កុហក់គេថាធ្លាក់ហើយខ្ញុំនោះ ពួកហ្នឹងយំ ដល់ម៉ោណោះទៀត នៀក ពួថារៀនសូត្រនៀក រៀនសូត្រដែលយកទៅហ្នឹណា៎ ពួកណោះយំទាំងអស់ សុទ្ធតែតាៗគាត់អាណិតគេទាំងអស់ តែម៉ោត្រង់ណាគេ អាណិតទាំងអស់ គាត់ឲ្យគេស៊ីឆ្អែតបានអញ្ចឹង បើមុនៗអត់ទេ គេដ្ឋន្ទាខ្ញុំពួនឹងត្រចៀកអញ្ចឹងនិយាយប្រាប់ខ្ញុំអស់ពួកហ្នឹង នេះអត់ទេ ពីដើមគេដាក់ ដូចថាកម្មាភិបាលគេមិនស៊ីឆ្ងាញ់ហ៎! គេដាក់ម៉ាបន្ទប់ហើយ បេកអីយកដាក់ សុខចិត្តទុកចោល ហ្នឹងមុនខ្ញុំអត់ដឹងទេរឿងគេនោះ ខ្ញុំអត់ដឹងទេ ។

**ឆៃរ៉ាន់ៈ** នៅណាហ្នឹង?

**យ៉េតៈ** នៅបាត់ដំបងនេះតើ ។

**ឆៃរ៉ាន់ៈ** ពេលគាត់ម៉ោពីពោធិសាត់វិញហ្នឹងហ៎?

**យ៉េតៈ** ចា៎ស! ទើបតែម៉ោ ដល់ពេលនេះទៅគាត់ៗឲ្យយកដាក់ការដ្ឋានចែកប្រជាជន ឲ្យចែកទៅដាក់ថង់មួយៗចែកកូនចៅ ណាសល់យកទៅកូនចៅផងទៅណា៎ អាទើបតែម៉ោពីធ្វើការវិញ ស្ករដកនោះ ម៉ោដល់ដាក់តុអញ្ចឹងទៅតំរៀបថង់ៗ ១០ នាក់ដាក់ ១០ ថង់ទៅ ។

**ឆៃរ៉ាន់ៈ** ពេលគេប្តូរគាត់ម៉ោខែ៧, ៧៧ ម៉ោបាត់ដំបងហ្នឹងគាត់ធ្វើខាងអីវិញទៅ?

**យ៉េតៈ** រទេះភ្លើងដដែលហ្នឹង ធ្វើស្រែដដែលហ្នឹង ចិញ្ចឹមជ្រូកទាអី ។

**ឆៃរ៉ាន់ៈ** កាលម៉ោបាត់ដំបងហ្នឹងនៅកន្លែងណាវិញពេលម៉ោហ្នឹង?

**យ៉េីត:** នៅរទេះភ្លើងហ្នឹង ។

**ឆៃវ៉ាន់:** នៅកន្លែងវ៉ាររទេះភ្លើងរាល់ថ្ងៃហ្នឹងហ៎?

**យ៉េីត:** ចា៎ស! នៅដូចគ្នាចុះគាត់នៅខាងហ្នឹងហើយ ប៉ុននេះនៅដដែលហ្នឹង ហើយធ្វើស្រែនៅខាង ចំការចេកណោះ ។

**ឆៃវ៉ាន់:** ចុះគាត់ខាងរទេះភ្លើងម៉េចមានសិទ្ធិឲ្យម្ហូបឲ្យអីដល់អ្នកស្រុកដែរ?

**យ៉េីត:** ចុះធ្វើស្រែនោះ ធ្វើបាននោះ ហើយគាត់ទៅនេះនោះ គាត់ទាក់ទងអ្នកពោធិសាត់មិនស្រុក ក្រគរ មិនបានត្រីៗគាត់មិនយកម៉ោឲ្យកូនចៅស្លហ្នឹង ស្លរួមមែនស្លឯកជនទេ ។

**ឆៃវ៉ាន់:** កូនចៅគាត់ហ្នឹងហ៎?

**យ៉េីត:** ចា៎ស! មែនថា ឲ្យចែកអ្នកនេះអ្នកនោះតាមផ្ទះណាអត់ទេ ចែករួមខ្ទះគ្មោតអញ្ចឹងទៅ បើថាកាប់ជ្រូកប្អូន ខាងពេទ្យដែលចិញ្ចឹមកុមារនោះចែកហ្នឹងទៅពីរ ហើយការដ្ឋានគាត់ពីរ បើ មាន់ដប់ដឹងតែ១០ៗដូចគ្នា អញ្ចឹងណា៎ ។

**ឆៃវ៉ាន់:** ចុះមីងកាលហ្នឹងគាត់ខាងរទេះភ្លើងប៉ុន្តែគាត់មានសិទ្ធិចែកមាន់ចែកអី?

**យ៉េីត:** ចុះបើថាគេឲ្យធ្វើស្រែហើយ គាត់ខាងរទេះភ្លើង គាត់មែនរទេះភ្លើងតែមុខទេ គាត់ទៅធ្វើស្រែនៅចំការចេកបងប្អូនប្រជាជនគេឲ្យចាត់ចែងទៅហ្នឹងណា៎ ហើយគាត់មើលខុសត្រូវអ្នក ណាអត់អ្នកណាមានហ្នឹងយករួមហ្នឹងនោះ របស់រួមហ្នឹងនោះ យកចែកកូនចៅស្ល ខាងពេទ្យ ម៉ាកន្ទុប ហើយខាងកុមារនោះម៉ាកន្ទុប ខាងកុមារកំព្រីកំព្រាអីចឹងទៅណា៎ កុមារតូចៗនោះ អី ។

**ឆៃវ៉ាន់:** អញ្ចឹងគាត់ខាងរទេះភ្លើងហើយគាត់ខាងចែកម្ហូបចែកអីតាមផ្នែកៗហ្នឹងដែរ?

**យ៉េីត:** គាត់ចាត់ចែងអញ្ចេយះណា៎ ខាងពេទ្យយកជ្រូកពីរទៅធ្វើម្ហូបឲ្យកូនចៅតូចៗណា៎ ខាងកុមារ នោះ យាយៗមើលកុមារនោះយកពីរធ្វើម្ហូបឲ្យកូនតូចៗ បបរដឹងតែព្រឹកឡើងដឹងតែបបរ ហើយណា៎ ទៅទាក់ទងត្រីងៀតឲ្យហ្នឹងម៉ាកន្ទុប ដូចថា ១០គីឡូម្នាក់ កន្លែងពេទ្យ១០គីឡូ កន្លែងកុមារតូចៗហ្នឹង១០គីឡូ កន្លែងការដ្ឋានខាងប្រុសហ្នឹង១០គីឡូ កន្លែងការដ្ឋានខាងស្រី ណោះ១០គីឡូអញ្ចឹងណា៎ ផ្នែកគេមានអញ្ចឹង ។

**ឆៃវ៉ាន់:** អញ្ចឹងគាត់ខាងរទេះភ្លើងហ្នឹងទៅដឹកឥវ៉ាន់ម៉ោចែកតាមផ្នែកៗនៅតាមបាត់ដំបងហ្នឹង?

**យ៉ើត:** ហ្នឹងគាត់ទាក់ទងគេណា៎ ទាក់ទងដូចអ្នកទៅរនាមទៅអីចឹងណា៎ ។

**ឆៃវ៉ាន់:** ទៅព្រៃរនាមជិតបឹងទន្លេសាបហ្នឹងហ៎?

**យ៉ើត:** ចា៎ស! គេមានផ្នែកគេតើហ្នឹងនោះ មានអ្នកនៅខាងណេះខាងណោះគេទាក់ទងបានម៉ោចែក ខាងប្រជាជន ហើយគាត់ចែកខាងរទេះភ្លើង អ្នកធ្វើការធ្ងន់ៗនោះ ខាងរទេះភ្លើងធ្វើការធ្ងន់ ដូចនៅអាដែងដូចនៅពោធិសាត់ ខាងព្រៃគប់ណា៎ គេអាចធ្វើធ្ងន់គាត់មិនឲ្យលែលកទៅ ហ្នឹងទៀត អញ្ចឹងតើ មែនថាធ្វើតែរទេះភ្លើង បើកតែរទេះភ្លើងណា៎ បើគាត់មើលទាំងអស់ គាត់មើលកូនចៅទាំងអស់ ។

**ឆៃវ៉ាន់:** អញ្ចឹងម៉ាររទេះភ្លើងហ្នឹង គាត់នៅបាត់ដំបងហ្នឹងគឺគាត់ធំជាងគេហ្មង?

**យ៉ើត:** មិនដឹងធំ មិនដឹងតូច បើឃើញតែអញ្ចឹង ។

**ឆៃវ៉ាន់:** កាលហ្នឹងគាត់មានកូនចៅអីច្រើនទេ?

**យ៉ើត:** កូនចៅក្រោមគាត់នោះ មិនចេះអត់ទេ ពេលថាទៅណាដូចថាទៅស្អី មើលខ្ញុំរកទឹកសិនទៅ បាណាន់ណា៎ កូនចៅគាត់បើកឡានជូនទៅ ។

**ឆៃវ៉ាន់:** ទៅលេងបាណាន់ហ៎?

**យ៉ើត:** ទៅលេងអី ទៅទាក់ទងស្អីៗ និយាយការងារគាត់ ខ្ញុំដឹងហ៎ ខ្ញុំមិនដឹងទេ គាត់និយាយពីនេះ ពីនោះទៅ គាត់និយាយឲ្យកូនចៅ បើកូនចៅណាអត់ទៅទាក់ទងយកអារបស់ហ្នឹងឲ្យកូនចៅ គាត់ហូបទៅណា៎ និយាយអញ្ចឹងតើ ដូចថាត្រូវការអីគេម៉ោហៅ គេជូនកូនចៅគាត់ជូនឡាន ទៅគាត់មានដែលដើរណាគាត់ ។

**ឆៃវ៉ាន់:** ដូចថាគាត់ប្រធានអញ្ចឹង អនុប្រធានគាត់ឈ្មោះអីលោកយាយដឹងទេ?

**យ៉ើត:** អត់ដឹងទេ អនុប្រធានគេ ឃើញតែប្រើទៅ ។

**ឆៃវ៉ាន់:** អត់ស្គាល់អនុប្រធានគេ?

**យ៉ើត:** ខ្ញុំដែលស្គាល់ បើខ្ញុំទៅក្រោយដែរ ទើបតែម៉ោយកជួបគ្នានេះ ខ្ញុំមិនដែលស្គាល់អ្នកតូចអ្នក ធំណា៎ ណាធំជាងណាខ្ញុំមិនដឹងទេ ខ្ញុំដឹងតែគាត់អញ្ចឹង ។

**ឆៃវ៉ាន់:** ចុះដូចថាខាងភូមិភាគខាងអីដែលម៉ោទំនាក់ទំនងគាត់ទេ?

**យ៉េតៈ** មាន តែមិនដឹងអ្នកណាទេ ខ្ញុំមិនដឹងទេ មានទាំងអស់ ម៉ោខាងណាៗ អ្នកណានៅស្រុកព្រៃ ណោះគេចែកផ្នែកគ្នាអញ្ចឹងណ៎ា ហ្នឹងក៏ម៉ោទាក់ទងដែរ ទាក់ទងទៅគាត់ណោះឲ្យគេទៅ ដល់គេមានអីគេឲ្យម៉ោទៅ ដូចថាហ្នឹងគេមិនសំបូរវិសត្ថុអីផ្ទះអីរមាំងអីឃើញដឹកទាំងឡានយក ម៉ោឲ្យដែរ ទាក់ទង ។

**ផៃវ៉ាន់ៈ** យកម៉ោមកឲ្យគាត់ទុកទៅ ?

**យ៉េតៈ** ចា៎ស!

**ផៃវ៉ាន់ៈ** ហើយគាត់ចែកតាមផ្នែកទៀតទៅ ?

**យ៉េតៈ** ចែកអី ដាក់ការដ្ឋានទៅ ។

វិដេ០១១៤

**យ៉េតៈ** ..........អញ្ចឹងហ៎េ យល់ទេ បើថាឲ្យគាត់ទៅរកខ្លួនគាត់ គាត់ទៅរកអត់បាន ។

**ផៃវ៉ាន់ៈ** គាត់អត់ទៅរកទេ គាត់គ្រាន់តែគេយកម៉ោទុកឲ្យគាត់ចឹងទៅ ហើយគាត់យកអាណើងបែងចែកតាមផ្នែក?

**យ៉េតៈ** ចា៎ស! គេយកម៉ោឲ្យ គេដឹកម៉ោណ៎ា ខ្ញុំមិនដែលស្គាល់ ស្គាល់តែគោ ដល់ឃើញទន្សោងខ្ញុំអត់ដែលស្គាល់ទេ ខ្ញុំស្គាល់ពោធិសាត់នេះតើ គេយកម៉ោមិនចេះតូចប៉ុណ្ណឹង ឯហ្នឹងសំបូរណាស់ គេទៅលើទៀតណ៎ា គេដឹកយកម៉ោឲ្យគាត់ ខ្ញុំថាឃើញក្បាល ខ្ញុំថាគោនោះអត់មានបូក បើឃើញទ្រឡុកទ្រឡនអញ្ចឹងនោះ ដល់រួចគាត់នោះវិផ្នែកទៅពេទ្យ ធំជាងគេពេទ្យហើយណ៎ា អ្នកណាច្រើនជាងគេគេកាត់ទៅអញ្ចឹងហើយ ពេទ្យហ្នឹងម៉ាកន្ទុប ហ៎! នេះការដ្ឋានខាងប្រុស នេះយុវជន នេះខាងមិត្តនារី នេះខាងអ្នកមើលកុមារ អញ្ចឹងតើ ស្តាប់ខ្ញុំនិយាយបានទេ ក្រែងលោខ្ញុំមិនសូវនិយាយផង ។

**ផៃវ៉ាន់ៈ** ចុះលោកយាយដែលព្រួសួរឈ្មោះហំអីទេ?

**យ៉េតៈ** ហំ, អត់ ។

**ផៃវ៉ាន់ៈ** គាវ៉ាញអីដែលព្រួទេ?

**យ៉េតៈ** ស្គាល់ គាវ៉ាញអីយកមាសទៅស្រុកណាអីខ្ញុំមិនដឹងទេ ។

**ផៃវ៉ាន់ៈ** គាវ៉ាញយកមាសទៅស្រុកណាម៉េច?

**យ៉េតៈ** ចុះជញ្ជូនម៉ាវីកហ្នឹង ជញ្ជូនមាសដាក់រូម ហើយយកទៅបាត់ទៅ បាត់ឈឹងទៅខ្ញុំមិនដែលស្គាល់ឃើញមុខផង ឃើញតែឈ្មោះ ឮតែឈ្មោះ ខ្ញុំមិនដែលទៅមើលអ្នកតូចអ្នកធំ ខ្ញុំខ្លាច សឹងស្លាប់ នៅដាំតែបាយហ្នឹង ។

**ឆៃវ៉ាន់:** ចុះតាកៅ អីដែលឮឈ្មោះទេ?

**យ៉េតៈ** ដែលតែឮ ។

**ឆៃវ៉ាន់:** ចុះតាគី?

**យ៉េតៈ** តាគីហ្នឹងក៏ហ្នឹងដែរ ។

**ឆៃវ៉ាន់:** តាប៉ែតអីដែលឮទេ?

**យ៉េតៈ** ឮ ។

**ឆៃវ៉ាន់:** ដឹងថាគាត់បីនាក់ហ្នឹងធ្វើការអីដែរអត់?

**យ៉េតៈ** អត់ដឹង ខ្ញុំមិនដឹងដែរ ខ្ញុំ១៧មេសា ។

**ឆៃវ៉ាន់:** តែធ្លាប់ឮឈ្មោះហ្នឹងដែរ?

**យ៉េតៈ** ឮ គេអ្នកដូចថាប្រជុំតែគ្នាគេណាណោខ្ញុំមិនដឹងទេ ។

**ឆៃវ៉ាន់:** ចុះតាក្អែងអីធ្លាប់ឮទេ?

**យ៉េតៈ** ឮ ។

**ឆៃវ៉ាន់:** ចុះតារ៉េន?

**យ៉េតៈ** អត់ទេ, តាក្អែងធ្លាប់ឃើញគាត់ទៅ គាត់ខ្មៅគាត់វៀងខ្មៅ ឃើញទៅ រៀនសូត្រពោធិសាត់ ហ្នឹងគាត់ទៅបង្រៀនគេណា៎ ខ្ញុំឃើញដែរ ខ្ញុំធ្វើបាយធ្វើអីហ្នឹងយកទៅ ។

**ឆៃវ៉ាន់:** គាត់ខាងអីដែរ?

**យ៉េតៈ** មិនដឹងហ្នឹងហើយថាខ្ញុំមិនដឹងទេ តែសួរអញ្ចឹងស្រេចហើយ ខ្ញុំមិនផ្អែកខាងហ្នឹងទេ ។

**ឆៃវ៉ាន់:** ចុះតាគីធ្លាប់ឃើញទេ?

**យ៉េតៈ** តាគីឃើញញឹកញាប់ជាងគេ ។

**ឆៃវ៉ាន់:** ឃើញគាត់នៅណា?

**យ៉េតៈ** ឃើញគាត់ម៉ោពោធិសាត់រៀនសូត្រហ្នឹង ។

**ផៃរ៉ាន់:** បង្រៀនគ្រូសារលោកយាយហ្នឹងហ៎?

**យើត:** រៀនទាំងអស់អ្នកធំតូចទាំងប៉ុន្មាន ។

**ផៃរ៉ាន់:** តាគឺហ្នឹងឈ្មោះដើមគាត់ឈ្មោះអីដែរ?

**យើត:** មិនដឹង អត់ស្គាល់គាត់ ។

**ផៃរ៉ាន់:** រៀងរ៉ូវគាត់យ៉ាងម៉េចដែរ?

**យើត:** រកថាមិនត្រូវ សម្បុរសណ្តែកបាយ ប៉ុនតាក្មេងគាត់ខ្មៅ ប៉ុនពេលរៀនសូត្រទេណ៎ា តែលើកបាយលើកទឹកទេ ខ្ញុំមិនជាអ្នកចំណាំទេ ។

**ផៃរ៉ាន់:** ចុះតារស់ ញុំមហ្នឹងធ្លាប់ឃើញគាត់ទេ?

**យើត:** អត់ ។

**ផៃរ៉ាន់:** តាកៅអីធ្លាប់ឃើញទេ?

**យើត:** តាកៅពុឈ្មោះប៉ុនមិនដឹង អត់ដែលឃើញ ឃើញតាគឺនិងតាក្មេងតែប៉ុណ្ណឹង ។

**ផៃរ៉ាន់:** ចុះដូចតាប៉ែតអីអត់ដែលឃើញមុខទេ?

**យើត:** អត់សោះ មិនដឹងនៅស្រុកណាណោះ ។

**ផៃរ៉ាន់:** ចុះពេលគ្រូសារលោកយាយត្រឡប់ម៉ោបាត់ដំបង ខែ៧ ៧៧ហ្នឹង គាត់នៅធ្វើខាងបាត់ដំបងហ្នឹងរហូតដល់ឆ្នាំណាទៅ?

**យើត:** រហូតឆ្នាំណាដែលគេយកទៅរៀនសូត្រនោះ រៀនសូត្រ៧៨ ថ្ងៃមួយកើត ខែមិយសិ ខ្ញុំដឹងខ្មែរថាអញ្ចឹង ប៉ុនបារាំងមិនដឹងអីទេ ។

**ផៃរ៉ាន់:** ពេលហ្នឹងម៉េចទៅ?

**យើត:** មានម៉េចគេជិះអាត្រែស៊ិនទៅតើ ។

**ផៃរ៉ាន់:** គេចាប់យកទៅ?

**យើត:** គ្មានចាប់ទេ ដែលចាប់ហ៎ ។

**ផៃរ៉ាន់:** គេហៅថាយកទៅរៀន?

**យើត:** គេហៅទៅនេះហើយហ្នឹង ទៅល្ងាចយប់ម៉ោង៥ហើយហ្នឹង ថាទៅពោធិសាត់ទៅយកតាអី ណោះមួយទៀត ភ្លេច ។

**ផៃរ៉ាន់:** ខាងណាដែលគេម៉ោហៅទៅរៀនសូត្រ?

**យ៉េត:** មិនដឹង ដឹងតែខាងភ្នំពេញៗ មិនដឹងខាងណា ខ្ញុំមិនស្គាល់ទេ ។

**នៃវ៉ាន់:** ខាងនិរតី ខាងពាយ័ព្យ?

**យ៉េត:** អត់ដឹងទេ ។

**នៃវ៉ាន់:** ដឹងតែគេម៉ោហៅគាត់ទៅ ?

**យ៉េត:** ចា៎ស!

**នៃវ៉ាន់:** ពេលដែលគេម៉ោហៅ លោកយាយនៅហ្នឹងដែរអត់?

**យ៉េត:** ខ្ញុំកើតកូនបាន២០ថ្ងៃ នៅហ្នឹងណា៎ ។

**នៃវ៉ាន់:** នៅជុំគ្នាជាមួយគាត់ហ្នឹង?

**យ៉េត:** នៅហ្នឹង ខ្ញុំកូនខ្ចីដែលនៅកើតហេ៎?

**នៃវ៉ាន់:** អញ្ចឹងម៉ោហៅពីផ្ទះទៅហេ៎?

**យ៉េត:** ថាហៅទៅរៀនសូត្រ គាត់ទៅប្រាប់ខ្ញុំនៅពេទ្យណា៎ ប្រាប់ថា អ៊ីអើយអ៊ីខ្ញុំទៅរៀនសូត្រ ហើយ គេគេម៉ោ ប្រាប់ថាអញ្ចេះណា៎ ដល់អញ្ចឹងខ្ញុំឡើងអាត្រៃស៊ីន ។

**នៃវ៉ាន់:** ត្រៃស៊ីនហ្នឹងអីគេ?

**យ៉េត:** ត្រៃស៊ីនហ្នឹងតូចៗខ្មៅៗ របៀបដូចរទេះភ្លើងហ្នឹងដែរ ។

**នៃវ៉ាន់:** ឡូរីហ្នឹងហេ៎?

**យ៉េត:** អាណឹងផ្សេងទៀត ឡូរីជិះបានតែពីរនាក់ទេ បើអាត្រៃស៊ីនជិះបាន៥នាក់អីបាន ។

**នៃវ៉ាន់:** គេដឹកគាត់តាមអាត្រៃស៊ីនហ្នឹងទៅ ?

**យ៉េត:** ចា៎ស! គេដឹកទៅរៀនសូត្រ គេមែនដឹកតែម្នាក់ទេ គេដឹកទៅពោធិសាត់ គេដឹកនៅហ្នឹង ម្នាក់ទៀតណា៎ ទៅ ។

**នៃវ៉ាន់:** គាត់ម៉ោប្រាប់ថាម៉េច?

**យ៉េត:** គាត់ប្រាប់អាថ្ងៃចេញ គាត់ប្រាប់ពេទ្យថាខ្ញុំទៅរៀនសូត្រហើយ គេឲ្យរៀនសូត្រ ដល់ពេល ចេញផុតទៅឮសូរតែគេថា ហ៎! នេះក្បត់ នោះក្បត់ ខ្ញុំយំទៅខ្ញុំមិនដឹងណាណៃ ។

**នៃវ៉ាន់:** ឮសូរថាគ្រួសារលោកយាយហ្នឹងក្បត់ដែរ?

**យើគៈ** ចេះតែថាទៅ ពួកនោះថាពួកនោះតែថាអញ្ចឹងទេមុខតែស្លាប់ហើយ តែថាគាត់ក្បត់ហ្នឹង វាស្លាប់អញ្ចឹង មនុស្សល្អណាស់ យាយៗតាៗគាត់យំហ៊ូរ និយាយជាមួយខ្ញុំ ខ្ញុំបើកភ្នែកអត់រួចទេ ហើមថ្ពុលបាត់ហើយ ចុះទើបតែបាន២០ថ្ងៃអូនអើយ! ទាំងគេទាំងឯង ។

**នៃវ៉ាន់:** ហ្នឹងកូនក្រោយហ្នឹងហ៎?

**យើគៈ** កូនអាដោយទៅ គេបាត់ហើយ អាហ្នុងហើយអាពៅ កើតបាន២០ថ្ងៃ តាំងពីហ្នឹងទៅ វារបូតដល់សព្វថ្ងៃទៅណា៎ ។

**នៃវ៉ាន់:** គេម៉ោហៅទៅរៀនអញ្ចឹងហ៎?

**យើគៈ** ទៅរៀនមែន, កាលហ្នឹងយកទៅរៀនមែនតើ ប៉ុនមិនដឹងរៀនអញ្ចឹងណាដឹងស្រាប់តែយូរ ទៅបានឃើញ បាន៧ថ្ងៃឃើញគេដឹកពីភ្នំពេញទៅ ឃើញកំបុតជើងកំបុតដៃនៀក ឈាមអី ផាប់អ្អែងមុខខ្ញុំហ្នឹង ។

**នៃវ៉ាន់:** អូហ៍! ពេលវៀតណាមចូលហ្នឹងឃើញគេដឹកមនុស្ស?

**យើគៈ** ដឹកមនុស្សទៅហ្នឹងហើយ ដឹកទៅដាក់មុខបាត់ដំបងហ្នឹងហើយ កន្លែងខ្ញុំនៅហ្នឹងហើយ ។

**នៃវ៉ាន់:** ឈប់នៅនឹងវ៉ាហ្នឹង?

**យើគៈ** ចា៎ស! ដឹកទៅវិញទៅ គាត់ហ្នឹងម៉ោផុតបាត់ហើយ គេដឹកទៅផ្សេងហើយ គាត់ម៉ោផុតហើយឃើញពួកហ្នឹងទៅទៀតណោះ ពួកអីក្រោយហ្នឹងណា៎ ខ្ញុំមិនដឹងទេ អ្នកក្រោយហ្នឹងទៅ ទៅសួរគេប្រាប់ខ្ញុំថា យាយហ្នឹងគាត់កើតកូនទេ ហើយប្តីទៅរៀនសូត្របាត់ហើយ ។

**នៃវ៉ាន់:** កាលលោកយាយសម្រាលកូនហ្នឹងនៅពេទ្យណាទៅ?

**យើគៈ** អូហ៍! ខ្ញុំមិនដឹងទេពេទ្យបាត់ដំបងហ្នឹងដែរ ។

**នៃវ៉ាន់:** ពេទ្យធំគេហ្នឹងហ៎?

**យើគៈ** ចា៎ស!

**នៃវ៉ាន់:** ពេទ្យព-២?

**យើគៈ** អូហ៍! ព-២នៅណោះ ។

**នៃវ៉ាន់:** ពេទ្យព-១?

**យ៉េតៈ** ឯណោះ ពេទ្យណោះនៅខាងណោះ ខ្ញុំនៅខាងកើត នៅខាងកើតវ៉ា ។

**នៃវ៉ាន់ៈ** រាល់ថ្ងៃគេហៅពេទ្យអី?

**យ៉េតៈ** មិនដឹងទេ ខ្ញុំមិនដែលទៅទេឥឡូវនោះ មិនដែលទៅពេទ្យទេ មិនដឹងគេហៅពេទ្យអីពេទ្យអីទេ ដល់សួរខ្ញុំអញ្ចឹងអត់ដឹងទេ កំពុងមនុស្សសសៃខ្ចីលែងដឹងអីហើយ ភ្នែកបើកមិនទាំងរួចផង ដូចថារៀនសូត្រៗ គាត់ប្រាប់ខ្ញុំ គាត់មិនហ៊ានប្រាប់អីណាគាត់ ខ្ញុំឮតែគេថាក្រោយឃើញ គេទៅឃើញអ្នកពួកទាហានកងទ័ពគេដែលគេទៅចូលហ្នឹងឃើញ ខ្ញុំសសៃខ្ចីងាប់ៗទៅ នឹកឃើញអញ្ចឹងតែភ្នែកខ្ញុំបើកមើលគេមិនឃើញ វាហើមខ្ទុលអស់ហើយហ្នឹង ទើបតែបាន២០ ថ្ងៃដូចដឹងស្រាប់ហើយ ។

**នៃវ៉ាន់ៈ** អញ្ចឹងគាត់បានចូលម៉ោប្រាប់ដែរថាគេហៅយកទៅរៀន?

**យ៉េតៈ** គាត់ខ្លាចខ្ញុំរក ព្រោះអីខ្ញុំនៅអាំងភ្លើងនោះ ខ្លាចរកបានទៅប្រាប់ថាខ្ញុំទៅរៀនសូត្រហើយ គាត់បានទៅអើតទេណ៎ ដល់អញ្ចឹងបាត់តាំងពីហ្នឹងទៅ ហ្នឹងដឹងតែថ្ងៃម៉ាកើត ។

**នៃវ៉ាន់ៈ** គាត់មានប្រាប់ថាខាងណាហៅទេ?

**យ៉េតៈ** គាត់មិនហ៊ានប្រាប់ទេខ្ញុំសសៃខ្ចីអញ្ចឹងនោះទើបតែបាន២០ថ្ងៃហ្នឹង ប្រាប់ម៉េចៗ ។

**នៃវ៉ាន់ៈ**

ចុះនៅពេលដែលគាត់ម៉ោប្រាប់ហ្នឹងតាមលោកយាយសង្កេតមើលទឹកមុខគាត់អីដូចថាលោក យាយដឹងថាគេបញ្ជូនយកទៅសម្លាប់អីក៏ម៉េច?

**យ៉េតៈ** គាត់ដឹងតែរៀនសូត្រ ។

**នៃវ៉ាន់ៈ** គាត់ម៉ោធ្វើធម្មតាអីចឹង?

**យ៉េតៈ** ចាស៎! ខ្ញុំសសៃខ្ចីខ្ញុំមានដឹងអី ទើបតែកើតបាន២០ថ្ងៃ, ២០ថ្ងៃគត់មើលអីមិនឃើញ ។

**នៃវ៉ាន់ៈ** ចុះក្រោយម៉ោប៉ុន្មានបានលោកយាយដឹងថាគេយកគាត់ទៅសម្លាប់?

**យ៉េតៈ** សព្វថ្ងៃក៏មិនដឹងដែរ ហោមើលចេះតែនៅៗគេទៅ ។

**នៃវ៉ាន់ៈ** អត់ទេ ដូចលោកយាយឮថា ដល់ពេលលោកយាយនាំគ្នាយំនោះ ជាមួយចាស់ៗផ្សេងៗទៀតនោះ?

**យ៉ើតៈ** អូហ៍! ពុអាគេថា ក្បត់ៗហ្នឹងពួកហ្នឹងចូលទៅ ។

**ណៃរ៉ាន់ៈ** ពួកខាងណាចូលទៅ ?

**យ៉ើតៈ** ពួកដែលថ្មី ដែលឃ្មួនអីស្អីៗហ្នឹងមិនដឹងណាណៃ ។

**ណៃរ៉ាន់ៈ** ចូលទៅដល់ក្នុងពេទ្យហ្នឹងប្រាប់ថាចាប់ ?

**យ៉ើតៈ** ប្រាប់ថា និយាយគ្នាគេណា៎ ។

**ណៃរ៉ាន់ៈ** ថាពួកពាយ័ព្យក្បត់ ?

**យ៉ើតៈ** ហ្នឹងហើយ ខាងណោះពាយ័ព្យហើយមុនគេ ក្រោយនិរតី ។

**ណៃរ៉ាន់ៈ** អូហ៍! និរតីចូលម៉ោហ្នឹងថាពួកពាយ័ព្យក្បត់ ?

**យ៉ើតៈ** ថាអញ្ចឹងហើយបានអញ្ចឹង ។

**ណៃរ៉ាន់ៈ** អញ្ចឹងពួកពាយ័ព្យអីក៏និរតីដែលហៅគ្រួសារលោកយាយទៅរៀនហ្នឹង ?

**យ៉ើតៈ** មិនដឹង បែបពួកនិរតីមិនដឹង បានណោះ៧ថ្ងៃទៅដល់ឈូរឆឈូរអី ខ្មោចឡើងក្រិះណោះឡើងអាខ្លះងាប់នៅនឹងគុរហ្នឹង បញ្ឈរភ្នែក ។

**ណៃរ៉ាន់ៈ** នៅនឹងពេទ្យហ្នឹង ?

**យ៉ើតៈ** នៅនឹងពេទ្យអីនៅអាមុខនេះនោះ ។

**ណៃរ៉ាន់ៈ**

អញ្ចឹងពេលគាត់ទៅរៀនសូត្របានរយៈពេលប៉ុន្មានថ្ងៃបានលោកយាយចេញពីពេទ្យម៉ា ?

**យ៉ើតៈ** ខ្ញុំអត់ទេ ខ្ញុំអត់ទេ គាត់ទៅដូចថាផុតថ្ងៃហ្នឹងស្អែកឡើងខ្ញុំម៉ោណា៎ ។

**ណៃរ៉ាន់ៈ** ម៉ោនៅកន្លែងរ៉ាហ្នឹងវិញ ?

**យ៉ើតៈ** ម៉ោនៅផ្ទះកន្លែងរ៉ាហ្នឹងវិញ ម៉ោស្រាប់តែ៧ថ្ងៃស្រាប់តែឃើញគេដឹកខ្មោចគរដូចគ្នាហើយ មុងនិយាយពិគេដឹកទៅណា៎ គេជញ្ជូនឲ្យអ្នកជំងឺហ្នឹងហើយ អ្នកកំបុតជើងកំបុតដៃតែជញ្ជូន ឯណា បើជញ្ជូនថ្ងៃហ្នឹងទៅងាប់នឹងគុរ ហើយមុងអីឡើងគរដូចអីអញ្ចឹងហើយខ្ញុំអត់ចុះម៉ោ រួចទេ ខ្ញុំគ្រាន់តែមើលពីលើម៉ោទេ ខ្ញុំអត់ចុះរួច ខ្ញុំទន់អស់ហើយខ្ញុំយំនោះ ខ្ញុំមើលពីលើ ផ្ទះហ្នឹងម៉ោណា៎ មើលទៅល្វោកល្វល់ ហើយឈាមដាបដូចអីចឹងដែលដឹកពីភ្នំពេញម៉ោវិញ ទេហ្នឹងនោះ មិនដឹងពីណាៗទេ ឃើញតែពីត្បូងទៅហ្នឹង ។

**ណៃវ៉ាន់:** ចុះពេលលោកយាយម៉ោពីពេទ្យវិញ ដូចថាពួកដែលធ្វើការជាមួយគ្រួសារលោកយាយនៅ រទេះភ្លើងហ្នឹងនៅដែរ ឬក៏បាត់អស់រលីងហើយ?

**យើគ:** មានតែបាត់អីទេ វាសុទ្ធតែពួកអ្នកត្រង់ដែរហ្នឹងបាត់ទៅណា៎ មានតែរត់ប្រសេចប្រសាចទៅអញ្ចឹង គ្រាប់ផ្លោះឃ្វាំងនោះ ។

**ណៃវ៉ាន់:** អញ្ចឹងគេហៅតែគ្រួសារលោកយាយម្នាក់ទេទៅរៀន អ្នកផ្សេងទៀតអត់ទៅទេ?

**យើគ:** អើ! គេឲ្យអ្នកធំទៅរៀន អ្នកបន្ទាប់ ។

**ណៃវ៉ាន់:** អ្នកនៅបន្ទាប់គ្រួសារលោកយាយនៅទេ?

**យើគ:** នៅ ប៉ុនឥឡូវងាប់អស់ហើយ ។

**ណៃវ៉ាន់:** ឈ្មោះអីគេអ្នកបន្ទាប់គ្រួសារលោកយាយ?

**យើគ:** ឈ្មោះអីទេ តែគ្រាន់តែជូនឡាន តែមិនដឹងគេធ្វើអីទេ ។

**ណៃវ៉ាន់:** និរសា?

**យើគ:** បែបហ្នឹងដឹង ឃើញតែជូនឡានទៅហ្នឹងនោះ ឃើញពេលទៅណាបើកឡានជូនទៅណាបើក ឡានជូន ម្នាក់នោះខាងរទេះភ្លើងហើយនិងអាត្រៃសិន ផ្នែកថ្នល់ណា៎ បើអាខាងផ្នែកឡាន ណោះតាមព្រៃណោះអ្នកនោះឡានបានទៅរួចនៅខាងរទេះភ្លើងមានម្នាក់ អ្នកបើករទេះភ្លើង ផ្សេង អ្នកបើកឡានផ្សេង ។

**ណៃវ៉ាន់:** អញ្ចឹងតាមដែលគេហៅទៅរៀនសូត្រហ្នឹងបាត់ដំណឹងរហូតម៉ោ?

**យើគ:** អូហ៍! អត់ដែលឮពីណាណៃទេ ខ្ញុំឡើងវង្វេងហើយ ខ្ញុំនិយាយមិនដឹងខុសត្រូវទេណា៎ កុំប្រកែប្រកាន់ខ្ញុំ ខ្ញុំនិយាយឡើងខ្ញុំចង់តែទឹកភ្នែក ។

**ណៃវ៉ាន់:** ចុះលោកយាយកាលជំនាន់ខ្មែរក្រហមគេឲ្យធ្វើអីដែរ?

**យើគ:** កាលដែលខ្ញុំទៅហ្នឹង ខាងឈរស្ទូឡើងហើមជើង ។

**ណៃវ៉ាន់:** អូហ៍! ខាងដាំស្ទូនៅកងរទេះភ្លើងហ្នឹងដែរ?

**យើគ:** ចា៎ស! មែនតែម្នាក់ទេមាន៣០នាក់ មានខាងចិតបន្លែ ចុះស្លាប់ហើយមនុស្សច្រើនណាស់ណា៎ ។

**ណៃវ៉ាន់:** ដាំឲ្យប្រជាជនហូប ឬក៏ដាំឲ្យកម្មកររទេះភ្លើង?

**យ៉ើគះ** កម្មកររទេះភ្លើង ហើយប្រជាជនដែលស្ទូងដកនោះ ម៉ាទៅរួមទាំងអស់ គេហូបរួមទាំងអស់តើ គេមែនហូបឯកជនណា៎ ។

**ឆៃវ៉ាន់ះ** បាទ! គេហូបរួមប៉ុនគេមានចែកដូចថាខាងកម្មករហូបផ្សេង អ្នកស្រុកហូបផ្សេងអីទេ?

**យ៉ើគះ** អ្នកស្រុកគេខាងគេផ្សេង អាណឹងគេហៅខាងយុវជន ខាងមិត្តនារី ខ្ញុំខាងយុវជនខាងរទេះភ្លើង ហើយនិងខាងស្ទូងដកខាងការងាររហ្នឹងខាងប្រុសៗទាំងអស់ណា៎ ។

**ឆៃវ៉ាន់ះ** ប្រហែលជាប៉ុន្មាននាក់ដែរដែលយាយធ្វើម្ហូបឲ្យហ្នឹង?

**យ៉ើគះ** អូហ៍! ច្រើនណាស់ បើពេលរៀនសូត្រឡើងរាប់ពាន់អីណោះ ធ្វើម្នាក់អីកើត ច្រើន ។

**ឆៃវ៉ាន់ះ** ចុះជាប្រចាំថ្ងៃយើងធ្វើប៉ុន្មានខ្ទះដែរ?

**យ៉ើគះ** បីខ្ទះ បាយបួនខ្ទះ ។

**ឆៃវ៉ាន់ះ** បាយទេ អត់មានបបរទេ?

**យ៉ើគះ** បាយដែលនេះហើយហ្នឹងនោះ ដែលគេធ្វើស្រែបានហើយហ្នឹង កាលមុនបបរ ។

**ឆៃវ៉ាន់ះ** ដល់ពេលខែធ្វើស្រូវអត់សូវបានបបរ?

**យ៉ើគះ** បបរតើហ្នឹង ចុះគ្នាលើកធ្ងន់នោះ បើពេលនេះបបរទៅៗលើអាឈើដាក់រទេះភ្លើងហ្នឹងរួច ។

**ឆៃវ៉ាន់ះ** ចុះម្ហូបអីលោកយាយទៅរកពីណាម៉ោ?

**យ៉ើគះ** ម្ហូបអីមិនព្រួខ្ញុំថាចិញ្ចឹមទេហេ៎ អ្នកហ្នឹងចិញ្ចឹមណា៎ ក្រុមដូចថាគេចាត់ខ្ញុំឲ្យចិញ្ចឹមជ្រូកម៉ាក្រុម ហើយទាហ្នឹងម៉ាក្រុម ចិញ្ចឹមមាន់នោះម៉ាក្រុម ពេលនេះទៅគេស្ទូងដក ម៉ោពីហ្នឹងមាន់ទាអី នៅលើអ្នកហ្នឹងតើ គ្មានណាចិញ្ចឹមទៀត មានតែអ្នកធ្វើការហ្នឹង ។

**ឆៃវ៉ាន់ះ** អញ្ចឹងលោកយាយចាំតែធ្វើម្ហូបទេ ផវ៉ាន់ធ្វើម្ហូបអីគេយកម៉ោឲ្យដល់កន្លែងធ្វើទៅ?

**យ៉ើគះ** ចា៎ស! ចុះនេះនោះបើគាត់អ្នកមើលការខុសត្រូវហើយ យកម៉ោអ្នករទេះភ្លើងអីហ្នឹងនោះធ្វើការហ្នឹង ប៉ុនគាត់ចិញ្ចឹមក្រុមគាត់ណា៎ ។

**ឆៃវ៉ាន់ះ** ចុះកាលជំនាន់ហ្នុងយាយបានហូបចុកឆ្អែតដែរអត់សូវពិបាកទេ?

**យ៉ើគះ** អត់អីទេ ខ្ញុំហូបដូចគេមិនបានទេ ក្តៅណាស់ ខ្ញុំអត់សូវស្រួលទេ ។

**ឆៃវ៉ាន់ះ** តែលោកយាយដូចថាអត់សូវអត់ទេ បានហូបជាប់ទេ?

**យើគៈ** ហូបពេលណាទៅខ្វះបបរ ពេលណាទៅដូចថាអង្ករតិចយើងបបរម្តងទៅណ៎ា ពេលណានេះ ទៅយើងធ្វើស្រែខ្លួនយើងអញ្ចឹងនោះ ពេលណាបានបាយក៏បាយទៅមែនថា ។

**នៃវ៉ាន់ៈ** តែដូចថាលោកយាយស្រួលជាពួកអ្នកនៅស្រុកភូមិ ដូចថាបានហូបឆ្អែត អត់សូវខ្វះ?

**យើគៈ** ខាងរទេះភ្លើងអញ្ចឹងឯង ។

**នៃវ៉ាន់ៈ** តែលោកយាយអត់មានធ្វើស្រែអីទេ?

**យើគៈ** ខ្ញុំនៅតែកន្ទែងបាយហ្នឹងហើយហ្នឹងនោះ ។

**នៃវ៉ាន់ៈ** រហូតតាំងពីដើមម៉ោ?

**យើគៈ** គេធ្វើបុណ្យដូចប្រជាជនអញ្ចឹង គេម៉ោរៀនសូត្រ ដូចអ្នកម៉ោរៀនសូត្រពីភ្នំពេញអីហ្នឹងណ៎ា ដឹងកន្ទែងបាយហ្នឹងបាត់ហើយ ។

**នៃវ៉ាន់ៈ** អញ្ចឹងអ្នករៀនសូត្រពីភ្នំពេញម៉ោធ្លាប់ម៉ោកន្ទែងហ្នឹងដែរ?

**យើគៈ** ម៉ោ ។

**នៃវ៉ាន់ៈ** ឈ្មោះអីខ្លះតាមលោកយាយចាំ?

**យើគៈ** ខ្ញុំអត់ស្គាល់ទេ ថាខ្ញុំនៅតែកន្ទែងបាយ ។

**នៃវ៉ាន់ៈ** ពួកគេដូចថាឋានៈគេប៉ុណ្ណាដែរ?

**យើគៈ** ខ្ញុំមិនដឹងដែរ ។

**នៃវ៉ាន់ៈ** ហើយគេរៀននៅណា, ពេលដែលគេម៉ោរៀនសូត្រហ្នឹងនៅណា? នៅពោធិសាត់អីក៏នៅ បាត់ដំបង?

**យើគៈ** ពីបាត់ដំបងក៏ទៅ ដូចទៅមួយៗណ៎ា ហើយគេហៅស្អី ដូចនៅខាងយើងប្រជាជនអញ្ចឹងគេ ហៅស្អីពីដើម, មិនដឹងគេហៅអី ហ្នឹងក៏ទៅដែរ គេទៅមួយៗអញ្ចឹងទៅណ៎ា ។

**នៃវ៉ាន់ៈ** មេគេហ្នឹងហ៎េ?

**យើគៈ** មិនដឹងមេមិនដឹងអីប៉ុន្តែទៅមួយៗអញ្ចឹងទៅ ។

**នៃវ៉ាន់ៈ** អ្នកដែលទៅរៀនដូចមានឈ្មោះអីខ្លះតាមលោកយាយដឹង?

**យ៉ើគះ** ចាំមើលបាត់ដំបងគេយកមួយទៅរៀនសូត្រ ហើយស្អីខាងនេះនោះខាងអារ៉ាញ់នោះមួយ ហ្នឹងខាងរទេះភ្លើងទេណ៎ា ។

**ឆៃវ៉ាន់:** អូហ៍! ទៅប្រជុំហ្នឹងតែខាងផ្នែករទេះភ្លើងទេ?

**យ៉ើគះ** ហើយគាត់ទៅរៀនសូត្រអញ្ចឹងដែរ ទៅភ្នំពេញហ្នឹងដែរ ហើយគេម៉ោបង្រៀនគេម៉ោហ្នឹង ដែរអញ្ចឹងណ៎ា ។

**ឆៃវ៉ាន់:** ចុះដូចថាខាងភូមិភាគខាងអីគេចុះម៉ោដែរ?

**យ៉ើគះ** ទៅ ត្រូវថ្ងៃណាទៅៗ អ្នកបាយនេះប្រុងតែរៀបទៅអញ្ចឹង ។

**ឆៃវ៉ាន់:** គេប្រាប់មុនអញ្ចឹងដែរ?

**យ៉ើគះ** ចា៎ស!

**ឆៃវ៉ាន់:** ចុះមីងប៉ុល ពត ខៀវ សំផនអីគេដែលទៅប្រជុំនៅហ្នឹងទេ?

**យ៉ើគះ** អត់ដែលស្គាល់ទេ ខៀវ សំផនអីខ្ញុំមិនទាន់ដឹង រាជមុនដឹងមិនដែលឃើញទេ ខ្ញុំស្គាល់តែតាកី តាអីហ្នឹង ។

**ឆៃវ៉ាន់:** តាកីហ្នឹងធ្លាប់ម៉ោប្រជុំហ្នឹងញឹកហ៎េ?

**យ៉ើគះ** គាត់ទៅរៀនសូត្រ គាត់ទៅបង្រៀនគេ ។

**ឆៃវ៉ាន់:** យាយធ្លាប់ចូលរួមរៀនជាមួយគេអត់?

**យ៉ើគះ** ខ្ញុំនោះ ខ្ញុំរៀនវគ្គផ្សេងៗតើ យើងទៅរៀនហ្នឹងម៉េចទាល់តែអ្នកខ្ពស់ៗណោះ ខ្ញុំទៅរៀនដូចពេទ្យដូចអី ដូចប្រធានៗក្រោមបន្ទាប់ ក្រោយៗកំប៉ិចកំប៉ុក ។

**ឆៃវ៉ាន់:** ចុះលោកយាយខាងដាំស្លហ្នឹងលោកយាយប្រធានគេអីក៏ម៉េច?

**យ៉ើគះ** អត់ទេ ឡូខ្ញុំធ្វើប្រធានខ្ញុំមិនធ្វើទេ ។

**ឆៃវ៉ាន់:** ឡូធ្វើដែរ?

**យ៉ើគះ** ឡូខ្ញុំធ្វើខ្ញុំមិនធ្វើ ។

**ឆៃវ៉ាន់:** អញ្ចឹងអ្នកណាគេប្រធានខាងដាំស្ល?

**យ៉ើគះ** ប្រធានអ្នកនិរតី ។

**ឆៃវ៉ាន់:** ចុះមុននិរតីចូលពីណាគេ?

**យ៉ើគះ** អូហ៍! ហ្នឹងពាយ័ព្យកាលប្ដីខ្ញុំហើយហ្នឹង គឹម ។

**ឆៃវ៉ាន់:** គីម ស្រីអីប្រុស?

**យើគៈ** ស្រី ប្តីឈ្មោះទីម ខាងរទេះភ្លើង ។

**ឆៃវ៉ាន់:** កូនចៅរបស់គ្រួសារលោកយាយ?

**យើគៈ** អ្ហូហ៍! មិនស្គាល់ទេ អ្នកលើដែរ ។

**ឆៃវ៉ាន់:** តែតួចដាងគ្រួសារលោកយាយទេទីមហ្នឹង?

**យើគៈ** ហ្នឹងនេះណោះ ធ្វើក្រោម គេធ្វើប្រធានដែរ តែប្រធាកំប៉ិចកំប៉ុកដូចខ្ញុំអញ្ចឹង ។

**ឆៃវ៉ាន់:** លោកយាយប្រធានដែរ?

**យើគៈ** ខ្ញុំប្រធានអីខ្ញុំ ។

**ឆៃវ៉ាន់:** ម៉ាខាងដាំស្លគេហ្នឹងមានគ្នាប៉ុន្មាននាក់?

**យើគៈ** ខ្ញុំនោះ ដូចយើងប្រជាជនអីចេះចឹងទៅ ជួយគ្នាតើ អ្នកស្រែទៅជួយនៅការដ្ឋានហ្នឹង មិន មែនអ្នកនេះអ្នកនោះឯណា ជួយធ្វើ ។

**ឆៃវ៉ាន់:** ថ្ងៃណាររវល់ច្រើនហៅជួយម៉ោធ្វើទៅ?

**យើគៈ** គ្នាច្រើនរៀនសូត្រអីណាទៅ ធ្វើកើតទាន់ ហើយអ្នកធំគេម៉ោអញ្ចឹង ។

**ឆៃវ៉ាន់:** ចុះធម្មតាប៉ុន្មាននាក់ដែរ ខាងដាំស្លពេលដែលអត់មានរៀនសូត្រ?

**យើគៈ** អ្ហូហ៍! មានរាប់រយ ។

**ឆៃវ៉ាន់:** គ្រាន់តែខាងដាំស្លហ្នឹងរាប់រយនាក់?

**យើគៈ** ទេ អ្នកដែលម៉ោហូបណាំ ។

**ឆៃវ៉ាន់:** ប៉ុន្តែអ្នកដែលខាងធ្វើម្ហូបហ្នឹងគ្នាប៉ុនាននាក់?

**យើគៈ** អ្ហូហ៍! ៣០ហ្នឹង ។

**ឆៃវ៉ាន់:** ៣០ នាក់, ប្រធានគេឈ្មោះគីមហ្នឹង, លោកយាយអនុ?

**យើគៈ** អត់ទេ ថាខ្ញុំអត់ធ្វើទេ ថាខ្ញុំគ្រាន់តែជំនួយទេ ។

**ឆៃវ៉ាន់:** ក្រៅពីគីមលោកយាយមានចាំឈ្មោះណាគេផ្សេងទៀតអត់?

**យើគៈ** អត់, អត់ស្គាល់ ហ្នឹងដោយសារដាំស្លជាមួយខ្ញុំទេ ហ្នឹងប្រធានទេ ធ្វើប្រធានទេ ខ្ញុំស្គាល់ ។

**ឆៃវ៉ាន់:** ចុះដល់ពេលដូរម៉ោបាត់ដំបងវិញលោកយាយនៅខាងដាំស្លដដែលអីក៏ខាងអី?

**យើគៈ** នៅចិតបន្លែហ្នឹងដដែល ។

**ឆៃវ៉ាន់:** ប្រធានហ្នឹងគឺមដដែល?

**យ៉េតៈ** ហ្នឹងដដែល ។

**ឆៃវ៉ាន់:** ដូរម៉ោជាមួយគ្នាដែរ?

**យ៉េតៈ** ម៉ោជាមួយគ្នា ។

**ឆៃវ៉ាន់:** ទាំង៣០ នាក់ហ្នឹងដូរម៉ោជាមួយគ្នាអីក៏?

**យ៉េតៈ** នេះអត់បាន៣០ ទេបាត់ដំបង គ្នាតិចដែរ ។

**ឆៃវ៉ាន់:** បានប៉ុន្មានដែរ?

**យ៉េតៈ** គ្នាប៉ុន្មានទេ ដល់ណោះស្រូវឯណាច្រើនបានៗ ។

**ឆៃវ៉ាន់:** ចុះពេលលោកយាយដូរម៉ោបាត់ដំបងហ្នឹងលោកយាយមានកូនចៅប៉ុនាននាក់ហើយ?

**យ៉េតៈ** ខ្ញុំមើលបាន ខ្ញុំកូនពីសង្គម២ បីផាប់មួយ ហ្នឹងបើនៅអាយុ៨ឆ្នាំ, ១០ឆ្នាំអីនៅឡើយទេ មើលទៅ អាមួយកើតបានបីខែ ។

**ឆៃវ៉ាន់:** ពេលម៉ោបាត់ដំបងហ្នឹងបានកូនបួននាក់អញ្ចឹង?

**យ៉េតៈ** អានោះទើបតែចេះអង្គុល អាមួយនោះទើបតែកើតហ្នឹងនោះ អាមួយ២០ថ្ងៃនោះ អានេះ ៩ថ្ងៃខ្ញុំបីលើរទេះ ខ្ញុំទើបនឹកឃើញ ហើយសុទ្ធតែអាចម៍ជ្រូកអីហ្នឹង ។ ដល់ម៉ោណោះបាន ប៉ុន្មានបានទំងន់ទៀត ទំងន់ទៀតវាទើបតែចេះអង្គុលនោះ អានេះនោះ ខ្ញុំញីកម៉ាឆ្នាំមួយ ។

**ឆៃវ៉ាន់:** ចុះនៅពេលឆ្លងទន្លេអញ្ចឹងគេឲ្យឈប់ប៉ុន្មានថ្ងៃដែរ?

**យ៉េតៈ** ខ្ញុំអត់មានបានឈប់ណា៎ គេមានណាឲ្យឈប់ យើងចង់ឈប់ៗទៅ ខ្ញុំមិនបានឈប់ផង ខ្ញុំ អត់ឈប់ទេ ខ្ញុំមិនឲ្យគេថាខ្ញុំទេ គេវាល់គ្នាគេឈប់នោះ គេម៉ោព្រៃគេថាគេខំតស៊ូណាស់ គេឈប់ហើយប្រពន្ធគេនោះ ខ្ញុំអត់ទេ ទៅចំការគេអំពៅ អំពៅប្រវែងណោះខ្ញុំទៅឆ្ការហ្នឹង ឆ្ការដូចអីចឹង ។

**ឆៃវ៉ាន់:** ចុះកូនទាំងអស់នៅជុំគ្នាអីក៏បែក? កូនធំៗនៅជាមួយដែរ?

**យ៉េតៈ** អត់ទេ ។

**ឆៃវ៉ាន់:** ទៅនៅខាងណាទៅ?

**យ៉េតៈ** កូនទើបតែពីរហ្នឹង បែកទៅណា កូនប៉ុនណោះ មិនញុំខ្ញុំថាបីខែទេហ៎ អាមួយបីខែ អាមួយ បាន៧ឆ្នាំ អា៨១នេះបានតែ៧ឆ្នាំទេដែលបែកទៅបាត់ហ្នឹង ថាខ្ញុំវេទនានឹងកូន ។

**ឆៃវ៉ាន់:** បាត់កូនបងហ្នឹងមួយ?

**យើត:** អត់ទេ បាត់បងអានេះមួយទៀត អាមួយកើតពីពោធិសាត់ហ្នឹងនោះ អាមួយកើតបានម៉ាឆ្នាំហើយដែលគេយកហ្នឹងនោះ ខ្ញុំថាមិនឲ្យទេ តែគេយកនោះ ខ្ញុំទើបតែបាន២០ថ្ងៃនោះ ។

**ឆៃវ៉ាន់:** ពេលគេយកហ្នឹងគេយកគ្រួសារលោកយាយហើយនៅ?

**យើត:** អានេះ៩រោជ អានោះម៉ាកើត ។

**ឆៃវ៉ាន់:** អញ្ចឹងយកកូនទៅមុន?

**យើត:** យកកូនទៅក្រោយ ។

**ឆៃវ៉ាន់:** យកប្តីខ្ញុំ៩រោជ យកកូនថ្ងៃម៉ាកើត?

**យើត:** មើលឪវាម៉ាកើតខែមិកសេ អានេះរនោជ ឯណោះម៉ាកើត អានេះរនោជ ខែបុស្ស ។

**ឆៃវ៉ាន់:** អញ្ចឹងយកប្តីទៅមុន ក្រោយម៉ោយកកូនទៅតាមក្រោយ?

**យើត:** ណោះរៀនសូត្រ ណោះមានតាមឯណាគេយកដេរ្សងហ្នឹង ។

**ឆៃវ៉ាន់:** គេយកធ្វើអីកូនហ្នឹង?

**យើត:** គេស្រឡាញ់ គេចង់បានៗយកទៅសាប់ទេកូនខ្ញុំនោះ ។

**ឆៃវ៉ាន់:** ម៉េចបានដឹងថាស្លាប់?

**យើត:** ចុះបើគេថាហើយ គេប្រាប់ឲ្យខ្ញុំទៅលេង ខ្ញុំថាមិនទៅទេ ខ្ញុំថាមិនទៅទេ យកកូនអញទៅសាប់ហើយ មីប្រធានហ្នឹងយកកូនខ្ញុំទៅ ។

**ឆៃវ៉ាន់:** អូហ៍! យកកូនហ្នឹងទៅ?

**យើត:** ចា៎ស!

**ឆៃវ៉ាន់:** រាល់ថ្ងៃកូនហ្នឹងអត់ដឹងថារស់អីក៏ស្លាប់ទេ?

**យើត:** សាប់ហើយ ដ្តាំម៉ោហើយ ខ្ញុំអត់ទៅទេឆ្ងាយណាស់ ។

**ឆៃវ៉ាន់:** នៅណា?

**យើត:** ឆ្ងាយណាស់ ។

**ឆៃវ៉ាន់:** ទើបតែព្រុដណឹងថាស្លាប់ក្រោយនេះអីក៏ស្លាប់ជំនាន់ខ្មែរក្រហម?

**យើត:** ទើបតែព្រុនេះឯង សាប់ៗហ្នឹងកំពុងតែអត់យួននោះ ខ្ញុំក៏អត់ដែរម៉ាវឹកហ្នឹងនោះ ខ្ញុំថាកុំឲ្យយកទៅ ត្បិតអីស្រុកប្តីខ្ញុំនៅនេះណា៎ កាលហ្នឹងខ្ញុំនៅបាត់ដំបងនោះ

ខ្ញុំពរអាកូននេះអាមួយ រំគិល អាមួយអញ្ចេះនេះ បី២០ថ្ងៃ នឹកឃើញអញ្ចឹងគេយកអាដើរហ្នឹង ធំណាស់ ហើយស ស្អុះ ខ្ញុំវេទនាណាស់ ជំនាន់ហ្នឹងគ្មានណាវេទនាដល់ខ្ញុំទេ ។

**ឆៃវ៉ាន់:** វេទនាម៉េចខ្លះទៅ ?

**យើ៉តៈ:** វេទនាអាយើង ។

**ឆៃវ៉ាន់:** ពេលយួនចូលហ្នឹងហេ៎ ?

**យើ៉តៈ:** ទេ! មែនយួនទេ កាលម៉ាហ៊ុកពេលស្អីហ្នឹងម៉ោ ។

**ឆៃវ៉ាន់:** និរតីម៉ោ ?

**យើ៉តៈ:** ចា៎ស! ម៉ោគេធ្វើការផារ ដូចយើងទៅអញ្ចឹងអត់មានកន្លែងស្អីយើងអ្នកថ្មីអញ្ចឹងណាស់ ហើយ ប្តីខ្ញុំទៅអញ្ចឹងយើងអ្នកថ្មី ហើយគេនោះសុទ្ធតែតស៊ូអីណាស់ ស្រីៗណាស់ ។

**ឆៃវ៉ាន់:**

ចុះលោកយាយពេលម៉ោដល់បាត់ដំបងហ្នឹងពេលហ្នឹងពួកនិរតីគេម៉ោហើយមែនពួកពាយ័ព្យ ទេណាស់ ?

**យើ៉តៈ:** អ្ហ៎! និរតីណាស់ទេ និរតីយកទៅ រៀនសូត្រណោះតើដែលម៉ោហ្នឹង ។

**ឆៃវ៉ាន់:** អញ្ចឹងពេលដែលម៉ោហ្នឹងនៅពួកពាយ័ព្យនៅ ឡើយទេ?

**យើ៉តៈ:** ខ្ញុំរត់ទៅណោះ ដល់ម៉ោនេះយួនចូលខ្ញុំរត់ទៅដំណាក់ ទៅភូមិអន្លុំណោះវិញណោះ បើមិន រត់ម៉េចបើឆេះនេះ ។

**ឆៃវ៉ាន់:** បាទ! ប៉ុន្តែពេលដែលគ្រួសារលោកយាយម៉ោខែ៧ ៧៧ ពេលហ្នឹងខាងពាយ័ព្យកាន់អីក៏ ខាងនិរតីកាន់?

**យើ៉តៈ:** នៅពាយ័ព្យតើ ដល់តែយួនចូលបានពួកនេះនិរតី យួនចូលគេម៉ោជាមួយគ្នាមិនដឹង ខ្ញុំអត់ ដឹងទេ ។

**ឆៃវ៉ាន់:** ចុះពេលដែលលោកយាយម៉ោនៅបាត់ដំបង

ហើយនិងនៅខាងពោធិសាត់ហ្នឹងពីរហ្នឹងណា ពិបាកជាង?

**យើ៉តៈ:** បាត់ដំបងកាលហ្នឹងមិនទាន់ធ្វើស្រែ វាដូចមេមុនមិននាំធ្វើ វាអត់អង្ករបន្តិចហើយ វាហូប បបរហើយ ហ្នឹងគេផ្លាស់ពីនោះម៉ោឲ្យបង្កបង្កើនផលហ្នឹងទៀត ផ្លាស់ឪហ្នឹងនោះ ។

**ឆៃវ៉ាន់:** ផ្លាស់ពីពោធិសាត់ឲ្យម៉ោប្រកប?

**យ៉េត:** ពីណោះគ្រាន់ទៅផ្លាស់ឲ្យម៉ោណោះឲ្យម៉ោកើតណោះទៀត បានឈប់បបរ បបរវាគ្មានកម្លាំង ដែរហ្នឹង ។

**ឆៃវ៉ាន់:** អញ្ចឹងនៅ បាត់ដំបងហ្នឹងបានបាយដែរ?

**យ៉េត:** ចា៎ស! ដល់បានទៅ បានៗ ហូបខ្លះទៅ ហើយបបរខ្លះទៅ បើអត់ដែលមានធ្វើសោះមេមុន គេកាន់ គេអត់ធ្វើម៉េច អ្នកមេក្រោយគេធ្វើ កូនចៅគេក្រោយគេធ្វើទៅបានទៅ បាន ហើយបានគេថា ម៉ូមសំបូរស៊ីណាស់ គ្នាខំ ខំឲ្យកូនចៅទាំងយប់ទាំងថ្ងៃបានៗ បាយហ្នឹង ចុះ បើមិនខំហ្នឹងបានកម្លាំងណាទៅ លើកឈើ កាប់ឈើដាក់រទេះភ្លើងអីហ្នឹង បានកើតអញ្ចឹងទៅ គេប្រណែនៗ ថាមាន ចុះយើងមិនធ្វើវាក្រទៅ ។

**ឆៃវ៉ាន់:** មានហ្នឹងបានគេហៅទៅរៀនហ្នឹង?

**យ៉េត:** ហ្នឹងហើយគេប្រណែនហ្នឹងហើយបានទៅរៀនហ្នឹងហើយ គេឃើញយើងស៊ី ប៉ុនយើងធ្វើតែ របស់ឯងទេណា៎ ហើយគេណោះ ហើយដាំល្ហុងនិយាយពីរឿងល្ហុងដាំ ពួកខាងហ្នឹងគេម៉ោ ខាងតាម៉ុក និយាយថាខាងតាម៉ុក ព្រល្បីថាខាងតាម៉ុកអញ្ចឹងខ្ញុំមិនស្គាល់ទេ ពួកហ្នឹងម៉ាសុំ ឃើញថាសំបូរស៊ីម៉ោសុំ ឲ្យល្ហុងតាហ្នឹងឲ្យទាំងបាវៗ ទៅទៀត ហ្នឹងសុទ្ធតែដាំខ្លួនឯងហ្នឹងណា៎ បានៗ ហ្នឹង កុំអីហ្នឹងហុតតែបបរហើយនិងល្ហុងហ្នឹងឯង ។

**ឆៃវ៉ាន់:** អញ្ចឹងឲ្យតែគាត់ទៅកាន់កន្លែងណា កន្លែងហ្នឹងស្រួល បានហូបបបូរ?

**យ៉េត:** ស្រួលមែនហ្នឹងណា៎ ស្រួលឡើងគេអាណិតឡើងយំល្ហេមល្ហាមតែអញ្ចឹងមិនចង់ឲ្យទៅណាអុជ ធូបពីក្រោយខ្នង មិនហ៊ានអុជនេះទេខ្លាចគេឮនោះ យំទាំងតែគ្នាហ្នឹង ។

**ឆៃវ៉ាន់:** ចុះលោកយាយពេលវៀតណាមចូលលោកយាយរត់ទៅដល់ណាទៅ?

**យ៉េត:** ភូមិអន្គ ចំការបេកភូមិអន្គ ។

**ឆៃវ៉ាន់:** ស្រុកណា?

**យ៉េត:** ជិតផ្សាហ្នឹងដែរ ខាងលិចផ្សា បើមិនរត់ទៅណាបើឆេះឃ្លាំងគ្រាប់មិនដឹងអ្នកណារត់មិនដឹង កូនខ្ញុំអីសុទ្ធតែរប៉ាត់រប៉ាយហើយ រត់ផ្សេងគ្នាទេ ខ្ញុំនេះបីកូនសំរទៅ ទៅដល់នោះគ្មានទេមុខ ខ្ញុំនោះមិនបាច់ទេដូចផ្សងម៉េចអញ្ចឹង ខ្ញុំនិយាយតាមត្រង់ថាដូចគូទឆ្នាំងម៉េចអញ្ចឹង វានេះ អស់ហើយ បែកស្រកាក៏បែក ។

**ផៃរ៉ាន់:** ទាស់ផងអីផង?

**យ៉េត:** ទាស់ហើយហ្នឹងនោះ ទាស់ហើយបានជាង២០ថ្ងៃដែលទ្រាំហ៉ើ អានេះដូចផ្សងម៉េចអញ្ចឹងឈាមឡើង ហើយខ្ញុំចេះតែយំហើយ យំឡើងហើមពពុល ហើយខំទេប្រវេរប្រវារអង្ករនោះ ខ្ញុំខំប្រវេរប្រវារណា៎ ទាំងសសៃរខ្ចីកូនខ្ញុំនៅតូចៗនោះ ដាក់អានេះចោល អានេះវារទៅ វារបានទន្សាយមួយលេងអាទន្សាយទៅ ។ ជញ្ជូនស្រូវម៉ោចិញ្ចឹមជីវិតអត់មានសោះ នៅឃ្លាំងគេដណ្តើមគ្នាដូចចោរអញ្ចឹង ជាមួយអាកូនខ្ញុំអាបងគេនោះឯងហើយនៅតូចដែរ នោះ ខំបានប្រកបាវយកម៉ោមួងតិចៗម៉ោ បែកស្រកានៅនឹងតើ ខ្ញុំថាតែងាប់ហើយតើ ខ្ញុំគិតលេបថ្នាំគេឃាត់មិនឲ្យលេប មែនខ្ញុំពិបាកចិត្តខ្ញុំ ខ្ញុំពិបាកនឹងស៊ីពោះឯង បើមិនអញ្ចឹង គេដណ្តើមគ្នាដូចអីចឹងអង្ករនិយាយពីដណ្តើមគ្នាដល់ហើយកាលហ្នឹង ថាដល់ហើយច្របល់ ច្របូកណាស់ មិនដឹងពួកណាៗអីទេ ។

**ផៃរ៉ាន់:** ចុះអត់មានរត់ទៅឆ្ងាយទេ រត់តែត្រឹមភូមិអង្គហ្នឹងទេ?

**យ៉េត:** ភូមិអង្គ ។

**ផៃរ៉ាន់:** ហើយឆ្នាំណាបានម៉ោដល់ស្រុកភូមិនេះវិញ?

**យ៉េត:** ប៉ុន្មានខែតើម៉ោវិញ ត្រឡប់ម៉ោបានប៉ុន្មានទេគេហៅឲ្យម៉ោចូលបាត់ដំបងកន្លែងហ្នឹងវិញហើយណា៎ ចូលឡើងនៅលើរទេះភ្លើងនោះ វាទូរៗនោះ ដេកនៅក្នុងរទេះភ្លើងទាំងអស់ឲ្យ តែណាម៉ោដេកទូរៗទៅ ដល់ពីហ្នឹងរួចទៅ គេថាឲ្យទៅស្រុកស្រែវិញ ខ្ញុំនេះបងប្អូនប្អូនថ្លៃ ខ្ញុំគេបរទេះទៅយកខ្ញុំម៉ោទេ ខ្ញុំសសៃខ្ចីទៅយកម៉ោដាក់អូរស្រឡៅនេះវិញម៉ោអញ្ចឹងណា៎ ។

**ផៃរ៉ាន់:** ចុះលោកយាយពេលម៉ោដល់ស្រុកភូមិនេះវិញ លោកយាយបាត់បង់បងប្អូនសាច់ញាតិអស់ ប៉ុន្មាននាក់?

**យើ៉ត:** ខ្ញុំបាត់កូន បាត់ប្អូនអត់មានទេ បងប្អូននិយាយពីបងប្អូនខ្ញុំបង្កើតនោះហ្នឹងធ្វើពីសម័យលន់ណុល ងាប់នឹងទាហាននោះ ។

**ឆៃរ៉ាន់:** អញ្ចឹងម៉ោវិញបាត់តែប្តី ហើយនិងកូនហ្នឹងមួយ?

**យើ៉ត:** ចា៎ស!

**ឆៃរ៉ាន់:** ចុះលោកយាយដូចថាត្រឡប់ម៉ោស្រុកភូមិវិញអញ្ចឹងលោកយាយគិតថារបបខ្មែរក្រហមហ្នឹងជារបបយ៉ាងម៉េចដែរ?

**យើ៉ត:** អត់ដឹងទេ សួរខ្ញុំនោះ ។

**ឆៃរ៉ាន់:** ពិបាកស្រួលអីម៉េច?

**យើ៉ត:** ខ្មែរក្រហមរបបហ្នឹងនោះហ៎ មិនដឹងទេ ។

**ឆៃរ៉ាន់:** លោកយាយគិតថារបបហ្នឹងស្រួលអីពិបាក?

**យើ៉ត:** ពិបាកស្រួលអីដូចតែខ្ញុំសព្វថ្ងៃនេះដែរ បើមិនធ្វើត្រូវអត់តែអញ្ចឹង ខ្ញុំសព្វថ្ងៃក៏អញ្ចឹងដែរទៅ ស្រណុកអីធ្វើតែហ្នឹងហើយ បានខ្ញុំថាមិនដឹងខាងណាស្រួល មិនដឹងខាងណាពិបាកទេ ។

**ឆៃរ៉ាន់:** ចុះកាលជំនាន់ខ្មែរក្រហមលោកយាយដែលឃើញគេចាប់មនុស្ស ធ្វើទារុណកម្មអីលោកយាយដែលឃើញទេ?

**យើ៉ត:** ហ្នឹងហ៎, អត់ដែលឃើញ បាបមាត់បុណ្យមាត់អីខ្ញុំមិនដែលឃើញទេ ព្រោះតែគេនិយាយមែនតែខ្ញុំមិនដែលឃើញសោះ ខ្ញុំនៅតែកន្លែងបាយហ្នឹងឯង ។

**ឆៃរ៉ាន់:** អញ្ចឹងលោកយាយគិតថារបបហ្នឹងមិនពិបាកដែរទេ ព្រោះបានហូបឆ្អែតដែរ?

**យើ៉ត:** ទេ! អាណឹងម៉ោពីខាងរទេះភ្លើងខំធ្វើស្រែខ្លួនឯងហ្នឹងហ៎ ម៉េចធ្វើស្រែខ្លួនឯង ។

**ឆៃរ៉ាន់:** តាមចិត្តលោកយាយគិតហ្នឹងគិតថាស្រួលអីក៏ពិបាក?

**យើ៉ត:** ស្រួលអីបើព្រុថាសម្លាប់គេអស់ហើយហ្នឹង ស្រួលម៉េចទៀត ។

**ឆៃរ៉ាន់:** ពិបាកដែរ?

**យើ៉ត:** សម្លាប់ចង់ខ្ទេ ព្រុសួរគេនិយាយអាណោចអាធមសឹងងាប់ហើយ មិនដឹងស្រួលអីទេអញ្ចឹងនោះ ខ្ញុំមិនដឹងស្រួលទេ ខ្ញុំហូបបបរទើបតែបានចិញ្ចឹមធ្វើស្រែខ្លួនឯងទេ បានហូបបាយម្តងម៉ាយាមអញ្ចឹងទៅកុំឲ្យធ្វើខាងរទេះភ្លើងធ្ងន់ហ្នឹងក៏គេមិនឲ្យហូបបាយដែរ ប្រជាជនព្រុគេថាទាញទាំងខ្ទេៗគិតម៉េចទៅ?

**ឆៃវ៉ាន់ៈ** អាណឹងពួគេនិយាយទេ?

**យ៉ើតៈ** ចា៎ស! ខ្ញុំអត់ដែលឃើញទេ ខ្ញុំនៅតែកន្លែងបាយ ។

**ឆៃវ៉ាន់ៈ** ពួនិយាយពេលណាដែរ?

វីដេ ១២៤

**ឆៃវ៉ាន់ៈ** អូហ៍! ពួនិយាយថាប្រជាជនគេទាញទាំងខ្សែៗអញ្ចឹងដែរ?

**យ៉ើតៈ** ចា៎ស!

**ឆៃវ៉ាន់ៈ** អ្នកដែលម៉ោនិយាយប្រាប់លោកយាយហ្នឹងឈ្មោះអីទៅ?

**យ៉ើតៈ** ដែលស្គាល់គេហ៎! ខ្ញុំនៅស្រុកណោះ គេនៅស្រុកណោះពួតែគេនិយាយ អ្នកដែលគេធ្លាប់នៅនេះណា៎ គេនៅជនបទអីចឹងណា៎ អូសទាញ ហើយប្ដីខ្ញុំនោះគេថាដាក់ពាងអីណាឲ្យពស់ ខាំអីណា ពួអញ្ចឹងទៀត បានថាវេទនាដែរ ។

**ឆៃវ៉ាន់ៈ** ពួថាគេដាក់ពាងម៉េច?

**យ៉ើតៈ** ពួថាយោលទោងអញ្ចេះប្រកក្នុងពាងផ្អក ដាក់ក្នុងទឹកត្រី ពួគេនិយាយដែរតើតែខ្ញុំមិនទៅឃើញខ្ញុំមិនដឹងដែរ ។

**ឆៃវ៉ាន់ៈ** ពួគេថាចាប់ប្ដីហ្នឹងដាក់ទឹកត្រី?

**យ៉ើតៈ** ពួថាឲ្យតែណាគេទៅទួលស្លែងដាក់ពាងអញ្ចេះទឹកត្រីមិនដាក់អញ្ចឹង ។

**ឆៃវ៉ាន់ៈ** អូហ៍! អញ្ចឹងពួដំណឹងថាគេយកប្ដីហ្នឹងទៅទួលស្លែងដែរ?

**យ៉ើតៈ** ទេ! ទើបតែពួក្រោយកាលមុនដឹងតែរៀនសូត្រ ។

**ឆៃវ៉ាន់ៈ** ទើបតែពួក្រោយពេលវៀតណាមចូលហ្នឹងហ៎?

**យ៉ើតៈ** ចា៎ស! ពួក្រោយទេ ពួក្រោយដែរនេះហើយ ពួគេថាយកទៅរៀនសូត្រហ្នឹងគេសម្លាប់អស់ហើយពួកអស់ហ្នឹងនោះ មិនអញ្ចឹងនោះ ចេះតែពួហើយ ប៉ុនយើងមិនផ្ទាល់នឹងភ្នែកណា៎ យើងនៅតែណោះតែអញ្ចឹងម៉ារបូតអញ្ចឹង ហើយថាយោលយោងអញ្ចេះដាក់ចូលក្នុងពាងអីចឹងចេះតែពួគេថាហើយ ។

**ឆៃវ៉ាន់ៈ** អូហ៍! ចងព្យួរជើងដាក់ចូលក្នុងពាងអីហ្នឹងហ៎?

**យ៉េតៈ** ចាស! ក្នុងពាងឲ្យដាក់ក្នុងទឹកត្រីម៉េចទេ ខ្ញុំឮតែគេនិយាយដែរទេណា៎ ហើយដាក់ឲ្យក្អែបខាំឲ្យពស់ខាំម៉េច ឃើញគេទៅមើល បងប្អូនជីដូនមួយខ្ញុំទៅមើលមែន ស្លាប់បាត់ហើយថាទៅ មើលមែន ។

**ផៃរ៉ាន់៖** ទៅឃើញទេ?

**យ៉េតៈ** គាត់ថាលោឃើញប្អូនគាត់ ប្អូនជីដូនមួយគាតនោះ ប្តីគាត់ប្អូនជីដូនមួយគាត់ ។

**ផៃរ៉ាន់៖** ទៅឃើញទេ?

**យ៉េតៈ** ទៅៗរកឈ្មោះវាអត់ឃើញ អត់ឃើញនៅអាគារពងហ្នឹងណា៎ បានខ្ញុំវេទនាប្តីខ្ញុំ គាត់មិនដែលធ្វើបាបអីទៅឲ្យគេដាក់អញ្ចឹង នឹកឃើញស្រណោះខ្លួនដែរ ។

**ផៃរ៉ាន់៖** ចុះលោកយាយម៉ោដល់សព្វថ្ងៃនេះ ដូចថាលោកយាយមានកូន មានចៅដែលកើត ដូចថាកូនកាលហ្នឹងកាត់នៅក្មេងៗដែរណា៎ អត់សូវដឹងច្បាស់ លោកយាយដែលនិយាយប្រាប់រឿងហ្នឹងឲ្យកូនឲ្យចៅដឹងឮដែរអត់?

**យ៉េតៈ** កូនសព្វថ្ងៃវាដឹង ឮតែគេនិយាយអញ្ចឹង ។

**ផៃរ៉ាន់៖** ចុះលោកយាយដែលនិយាយប្រាប់ទេ?

**យ៉េតៈ** ខ្ញុំគ្មានដែលនិយាយណាបើខ្ញុំគិតតែខំចិញ្ចឹមកូនអញ្ចឹង ព្រោះខ្ញុំឮគេថាដែរ ដូចតែគ្នាខ្ញុំហ្នឹងលែតែខំចិញ្ចឹមកូនដូចតែគ្នាអីចឹង ។

**ផៃរ៉ាន់៖** បាទ! តែដូចថាលោកយាយធ្លាប់និយាយប្រាប់កូនពីរឿងរបស់លោកយាយពីជំនាន់ខ្មែរក្រហម គ្រួសាររបស់លោកយាយអីដែលនិយាយប្រាប់ទេ?

**យ៉េតៈ** និយាយប្រាប់ថាទាញខ្សែទាញអីហ្នឹង ដល់ឮថាប្តី ឮថាស្លាប់ទួលស្លែងប្រកទឹកត្រីខ្ញុំនិយាយប្រាប់ដែរតើកូនខ្ញុំ ថាគេយកយ៉ាងណា គេដាក់ក្នុងពាងយ៉ាងណាទេ ។

**ផៃរ៉ាន់៖** និយាយទៅកូនជឿថា ពិតទេ?

**យ៉េតៈ** កូនចេះតែជឿហើយព្រោះមនុស្សឡើងអស់ហើយ និយាយមិនជឿម៉េចបើទាញទាំងខ្សែគេថាខ្សែគោម៉េច ។

**ផៃរ៉ាន់៖** ចុះលោកយាយរាល់ថ្ងៃនេះដែលឮពត៌មានតាមទូរទស្សន៍ តាមរយៈអ្នកស្រុកអីគេនិយាយពីរឿងតុលាការកាត់ទោសខ្មែរក្រហមៗអីដែលឮទេ?

**យ៉េតៈ** ខ្ញុំអត់ដែលមានវ៉ាឌីយ៉ូទេ ។

**ផៃរ៉ាន់:** ចុះដែលឮអ្នកស្រុកគេនិយាយគ្នាពីរឿងហ្នឹងទេ?

**យើត:** អត់ ខ្ញុំនៅតែផ្ទះនេះ ខ្ញុំមិនដែលទៅណា៎ បើខ្ញុំវង្វេងវង្វាន់ដែរ ។

**ផៃរ៉ាន់:** លោកយាយរាល់ថ្ងៃនេះខាងរដ្ឋាភិបាល
និងអង្គការសហប្រជាជាតិគេរៀបចំតុលាការដើម្បី
កាត់ទោសពួកមេដឹកនាំខ្មែរក្រហមដូចជានួន ជា, អៀង សារី, តាម៉ុក ខៀវ សំផនអីហ្នឹង
ណា៎លោកយាយ, គេរៀបចំដើម្បីកាត់ទោសពួកមេដឹកនាំអស់ហ្នឹង តើចំពោះលោកយាយ
ផ្ទាល់វិញតើលោកយាយគាំទ្រចង់ឲ្យមានការកាត់ទោសពួកមេដឹកនាំជាន់ខ្ពស់នាំខ្មែរក្រហម
ហ្នឹងដែរអីក៏អត់ទេ ចំពោះចិត្តលោកយាយផ្ទាល់ណា៎?

**យើត:** ចិត្តខ្ញុំនោះ ខ្ញុំចង់មែនអ្នកណាអាក្រក់ចង់តែធ្វើតាមហ្នឹងឲ្យដូចប្តីខ្ញុំ បើប្តីខ្ញុំស្លូតត្រង់ហើយ
ម៉ោធ្វើបាប ខ្ញុំនឹកឃើញអញ្ចឹង ខ្ញុំតូចចិត្តវាសនាខ្ញុំ នឹកឃើញស្លូតធ្វើអីបើស្លូតគេយកទៅ
សម្លាប់មុនអាក្រក់អាវៀចណោះ មែនណា៎ ខ្ញុំក្តៅណាស់ ។

**ផៃរ៉ាន់:** អញ្ចឹងចិត្តលោកយាយចង់ឲ្យមានការកាត់ទោសពួកអស់ហ្នឹងដែរ?

**យើត:** កុំចង់ឲ្យមានតទៅទៀត ។

**ផៃរ៉ាន់:** កាត់ទោសពួកហ្នឹងដើម្បីកុំឲ្យមានរបបហ្នឹងទៀត?

**យើត:** ចា៎ស! ចង់ទៅធ្វើឲ្យសប្បាយ ឲ្យប្រជាជនយើងសប្បាយ បងប្អូនយើងជុំរុំគ្នាកុំឲ្យព្រាត់
ប្រាស់បែកបាក់គ្នាណា៎ បើខ្ញុំចេះតែបែកបាក់អញ្ចឹងបានខ្ញុំមិនចេះបានសុខនឹងគេ ធ្វើត្រង់
ហើយនៅមិនសុខ ខ្ញុំចង់ឲ្យត្រង់ទាំងអស់គ្នា ។

**ផៃរ៉ាន់:** ចុះលោកយាយយល់ម៉េចដែរចំពោះពាក្យថាយុត្តិធម៌?

**យើត:** យុត្តិធម៌អ្នកត្រង់ហោ៎ ហើយអាអ្នកវៀចវាម៉េច អាអត់វាមិនធ្វើអញ្ចេះហោ៎ ខ្ញុំមិនដឹងទេ ខ្ញុំ
វង្វេងហើយ រកយុត្តិធម៌រកផ្លូវត្រង់ ។

**ផៃរ៉ាន់:** ចុះលោកយាយគិតថា តុលាការកាត់ទោសខ្មែរក្រហមហ្នឹងវាមានប្រយោជន៍អីខ្លះចំពោះ
លោកយាយ ចំពោះអ្នកស្រុកអ្នកភូមិ ចំពោះប្រទេសជាតិទាំងមូល?

**យើត:** ខ្ញុំអត់ចេះទេ សួរខ្ញុំច្រើនពេកខ្ញុំអត់ដឹងទេ ខ្ញុំល្ងង់ទេ ខ្ញុំល្ងង់ខ្លៅ ។

**ផៃរ៉ាន់:** ខ្ញុំដូចជាអស់អ៊ីចង់សួរលោកយាយហើយ លោកយាយមានអ៊ីចង់បន្ថែមបញ្ជាក់ប្រាប់ពួកខ្ញុំនូវអ៊ីដែលលោកយាយគិតថាវាឈឺចាប់ជិនាន់ហ្នឹង ហើយខ្ញុំអត់ទាន់បានសួរលោកយាយ លោកយាយមានអីចង់បញ្ជាក់ពួកខ្ញុំទៀតមានអត់?

**យើត:** ខ្ញុំនិយាយចប់ហើយ នឹកឃើញកំសត់ វេទនាណាស់ យកកូនឯងទៅទៀត យកទៅសម្លាប់ទៀត មែនសម្លាប់ទេអានេះអត់ហូប យកទៅចាក់ដាក់ចោល ហើយយើងចេះតែដើរបាត់ទៅ យកកូនខ្ញុំទៅអញ្ចឹង ខ្ញុំនឹកឃើញចេះតែតូចចិត្ត បើខ្ញុំនេះចេះចិញ្ចឹមកូនប៉ុនកដែកដើងម៉េចក៏ចេះរកឲ្យកូន ចេះរស់ម៉ោដែរ បើនេះត្រឡូកត្រលន់បើគ្នាថាមិនឲ្យយកទៅចេះតែយកទៅ ឯងសសៃខ្ទីចេះតែយកទៅឲ្យទៅងាប់ដែរ មិនឲ្យស៊ីណា៎ លែសប្បាយជួបបងប្អូន គេ ។

**ផៃរ៉ាន់:** ចុះអ្នកយកទៅហ្នឹងគេអត់មានកូនទេបានគេយកកូនរបស់លោកយាយ?

**យើត:** អត់មានទេ ប៉ុនវាមិននេះទេ ពុតែគេនិយាយដែរនោះ យើងមាត់ចាបមាត់ព្រាបពុតែគេថាដាក់កូនចោលកូនអី ណោះលែអបអរសាទ័របងប្អូនគេណា៎ ។

**ផៃរ៉ាន់:** តែដឹងច្បាស់ថាកូនហ្នឹងស្លាប់ហើយ?

**យើត:** ចា៎ស! គេទើបតែប្រាប់ដែរ ប្រាប់ប៉ុន្មានខែមុននេះ ។

**ផៃរ៉ាន់:** ចុះលោកយាយអត់ដែលទៅតាមរកកូនទេ?

**យើត:** ខ្ញុំដែលទៅរួចហ៎ា វង្វេង ទៅឆ្ងាយឥឡូវវិលមុខ ទើបតែបានគ្រាន់អន់វិលទេ ឈឺម៉ោពីមូលហេតុពិបាកចិត្ត ចេះតែរាំរៃណា៎ ។

**ផៃរ៉ាន់:** អញ្ចឹងខ្ញុំអរគុណលោកយាយច្រើនចំពោះអ៊ីដែលលោកយាយដែលនិយាយ ។

**យើត:** បើខ្ញុំនិយាយខុសឆ្គងអី ខ្ញុំនិយាយភ្លេចមុខភ្លេចក្រោយ ។

**ផៃរ៉ាន់:**

អញ្ចឹងពួកខ្ញុំអរគុណលោកយាយច្រើនដែលលោកយាយផ្ដល់ពត៌មានទាក់ទងនឹងគ្រួសាររបស់ លោកយាយ និងទាក់ទងនិងប្រវត្តិលោកយាយផ្ទាល់ដែលទាក់ទងនឹងរបបខ្មែរក្រហមហ្នឹងឲ្យ ពួកខ្ញុំដឹង ។ អញ្ចឹងអរគុណលោកយាយច្រើន ។

**យើត:** ចា៎ស!

**ចប់**